**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍន៍វិស័យការងារ
# ដែលមានឥទ្ធិពលដល់កំណើនសេដ្ឋកិច្ចនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ម៉ាប់ ម៉ារឌី**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍
ជំនាន់ទី ៥

ឆ្នាំសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ម៉ាប់ ម៉ារឌី ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី០៥ ក្រុម $D_4A_1$ ឆ្នាំសិក្សា ២០២០-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

១ លោកឪពុក .**ជា ម៉ាប់** និងអ្នកម្ដាយ **អ៊ិន សារ៉ាន** ដែលបានផ្តល់កំណើត និងខិតខំប្រឹងប្រែង ចិញ្ចឹមបីបាច់ថែរក្សា រួមទាំងផ្តត់ផ្គង់ការសិក្សាតាំងពីថ្នាក់បឋមសិក្សារហូតបានថ្នាក់មហាវិទ្យាល័យ។

២. ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងមន្ត្រីរាជការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងបង្រៀន និងណែនាំដល់ រូបខ្ញុំបាទ។

៣ លោកសាស្ត្រាចារ្យណែនាំ .**បណ្ឌិត ឈុន ពហុ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បី ពិនិត្យផ្តល់យោបល់ និងកែតម្រូវចំណុចខ្វះខាត តាំងពីចំណុចសេចក្តីផ្តើម ដល់សេចក្តីបញ្ចប់។

៤ .រាមច្បង អ្នកសិក្សាស្រាវជ្រាវទាំងអស់ដែលបានបន្សល់ទុកនូវឯកសារស្រាវជ្រាវនិងអត្ថបទវិចារណកថាជា ច្រើនទៀតដែលបានផ្តល់ជាមុនគំនិតឲ្យខ្ញុំ នៅក្នុងការសិក្សា និងស្រាវជ្រាវនេះ។

៥ .មិត្តភក្តិ និងមិត្តរួមថ្នាក់ ដែលតែងតែផ្តល់ជាគំនិត និងផ្លោះផ្តង់យោបល់គ្នាកន្លងមក។

ជាចុងក្រោយ ខ្ញុំបាទសូមគោរពជូនពរដល់លោកឪពុក និងអ្នកម្ដាយឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យបង្រៀន និងណែនាំ រាមច្បង និងមិត្តភក្តិទាំងអស់ ឲ្យជួបតែសំណាងល្អ សុខសុភមង្គល និងជួបតែពុទ្ធពរ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## **អារម្ភកថា**

បន្ទាប់ពីចំណាយពេល៤ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍នៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចមក ខ្ញុំពិតជាទទួលបាននូវចំណេះដឹងយ៉ាងច្រើនពីសាស្ត្រាចារ្យដែល បានបង្ហាត់បង្រៀនផ្នែកសេដ្ឋកិច្ច និងនយោបាយ។ នៅក្នុងពេលសិក្សា អ្វីដែលធ្វើឲ្យខ្ញុំមានការចាប់អារម្មណ៍ ជាងគេ នោះគឺការប្រព្រឹត្តទៅនៃនយោបាយសារពើពន្ធ និងជាពិសេសគឺគោលនយោបាយរូបិយវត្ថុ របស់ ធនាគារជាតិនៃកម្ពុជា ដែលជាចំណុចសំខាន់នៅក្នុងការជួយសេដ្ឋកិច្ចជាតិឲ្យមានការរីកចម្រើន។ អាស្រ័យ ហេតុនេះ ទើបខ្ញុំសម្រេចចិត្តសាកល្បងសិក្សាស្រាវជ្រាវលើប្រធានបទនេះ៖ "**ស្ថានភាព និងការអភិវឌ្ឍន៍វិស័យការងារ ដែលជះឥទ្ធិពលដល់កំណើនសេដ្ឋកិច្ចកម្ពុជា**" ដោយពិនិត្យមើលលើទិដ្ឋភាពទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង។

ជាការពិត ប្រទេសកម្ពុជាជាប្រទេសដែលទើបតែងើបចេញពីភ្នក់ភ្លើងសង្គ្រាមដែលស្ទើរតែបានបំផ្លាញ អ្វីៗគ្រប់យ៉ាងអស់ទៅហើយនៅក្នុងប្រទេសមួយនេះ។ ដោយឡែកសេដ្ឋកិច្ចកម្ពុជា ទើបតែទទួលបាននូវការរីក ចម្រើនគួរឲ្យកត់សម្គាល់នៅក្នុងរយៈកាល១ទសវត្សរ៍ចុងក្រោយនេះប៉ុណ្ណោះ ដែលអ្វីៗនៅមិនទាន់មានភាពរឹង មាំនៅឡើយ។ ចំណេរ តទៅ មានតែការខិតខំប្រឹងប្រែង សាមគ្គីគ្នា ការបង្កើនធនធានមនុស្ស និងបង្កើនឯករាជ្យភាពនៃគោលនយោបាយនានា ជាពិសេសទំហំការនៅក្នុងប្រទេសកម្ពុជាមានការកើនឡើងឥតឈប់ឈរ ដែលអាចឲ្យកម្ពុជាទទួលបាននូវការរីកចម្រើនដ៏ពេញលេញមួយ។

ខ្ញុំសង្ឃឹមថា ឯកសារស្រាវជ្រាវមួយនេះ នឹងក្លាយជាឯកសារដែលផ្តល់ផលប្រយោជន៍ដល់មិត្តនិស្សិត និងអ្នកសិក្សាស្រាវជ្រាវក្រោយៗក្នុងការសិក្សាបន្តទៀត។

បើទោះបីជាខ្ញុំ ខិតខំពិនិត្យពិច័យល្អិតល្អន់យ៉ាងណាក៏ដោយ ក៏ប្រហែលជាឯកសារនេះនៅមាន ចំណុចខ្វះខាត ឬខុសអក្ខរាវិរុទ្ធ និងមិនច្បាស់អត្ថន័យត្រង់ណាមួយជាពុំខាន។ អាស្រ័យហេតុនេះ សូមអ្នកអាន អ្នកសិក្សា មេត្តាអធ្យាស្រ័យដល់ខ្ញុំបាទផង។ ខ្ញុំបាទសូមទទួលរាល់ការរិះគន់ក្នុងន័យស្ថាបនាទាំងអស់ ដើម្បីឲ្យឯកសារស្រាវជ្រាវនេះកាន់តែមានភាពច្បាស់ការ។

# មាតិកា

**ទំព័រ**

បញ្ជីតារាង........................................iv

បញ្ជីរូបភាព........................................v

បញ្ជីក្រាហ្វ........................................vi

## សេចក្តីផ្តើម

**១**. លំនាំបញ្ហា........................................១

២. កម្មវត្ថុនៃការស្រាវជ្រាវ........................................២

៣. ចំណោទបញ្ហានៃការស្រាវជ្រាវ........................................២

៤. សារសំខាន់នៃការស្រាវជ្រាវ:........................................២

៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ........................................២

៦. វិធីសាស្ត្រស្រាវជ្រាវ........................................២

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........................................៣

## ជំពូកទី១ ការសិក្សាលើផ្នែកទ្រឹស្តី

១. ១. និយមន័យ........................................៤

១.១.១. ការអភិវឌ្ឍន៍........................................៤

១.១.២. ការអភិវឌ្ឍន៍ជនបទ........................................៤

១.១.៣. គោលបំណងនៃការអភិវឌ្ឍន៍........................................៥

១.១.៤. ទ្រឹស្តីសំខាន់ៗនៃការអភិវឌ្ឍន៍........................................៦

១.២. ទំនាក់ទំនងរវាងវិស័យការងារ និងកំណើនសេដ្ឋកិច្ច........................................៨

១.២.១. ការកើនឡើងនៃសេដ្ឋកិច្ច ........................................................................................៩

១.២.២ ធាតុផ្សំសំខាន់ៗដែលធ្វើអោយមានកំណើនសេដ្ឋកិច្ច .................................................១១

## ជំពូកទី២ ស្ថានភាពទូទៅនៃវិស័យការងារ

២.១. ស្ថានភាពទូទៅនៃវិស័យការងារ ........................................................................... ១៣

២.១.១. ការផ្គត់ផ្គង់កំលាំងពលកម្ម ............................................................................... ១៣

២.១.២.ប្រជាជនស្ថិតក្នុងវ័យធ្វើការ ..................................................................................១៤

២.១.៣.កំរិតអប់រំនៃប្រជាជនស្ថិតក្នុងវ័យធ្វើការ.......................................................................១៥

២.១.៤.ស្ថានភាពសេដ្ឋកិច្ច និងការងារ ...............................................................................១៦

២.១.៥.ស្ថានភាពការងារទៅតាមវិស័យ..............................................................................១៦

២.១.៦. ការប្រែប្រួលប្រាក់ឈ្នួល......................................................................................១៨

២.១.៧. ការប្រែប្រួលផលិតភាពការងារ...............................................................................១៩

២.១.៨.ស្ថានភាពទេសន្តរប្រវេសន៍ការងារ ........................................................................២០

២.២. កំណើនសេដ្ឋកិច្ចកម្ពុជា ........................................................................................២០

២.២.១. កំណើនផលិតផលក្នុងស្រុកសរុប(GDP) ..............................................................២១

២.២.២. ផលិតផលក្នុងស្រុកក្នុងប្រជាជនម្នាក់ៗ..................................................................... ២២

## ជំពូកទី៣ ការសិក្សាលើលទ្ធផលនៃការស្រាវជ្រាវ

៣.១. គុណសម្បត្តិរបស់វិស័យការងារ.................................................................................២៤

៣.២.បញ្ហាប្រឈមក្នុងទីផ្សារការងារ ..................................................................................២៦

៣.៣. ឥទ្ធិពលវិស័យការងារលើកំណើនសេដ្ឋកិច្ច ..............................................................២៩

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន......................................................................................................................៣៣

២.ការផ្តល់អនុសាសន៍ ......................................................................................................................៣៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

តារាង២. ១. ចំនួនប្រជាជនសរុបទៅតាមក្រុមមនុស្ស នៅចន្លោះឆ្នាំ២០១៣ និង ឆ្នាំ២០១៨ ........................................ ១៤

តារាង២. ២. កម្រិតអប់រំរបស់ប្រជាជនស្ថិក្នុងវ័យធ្វើការ(១៤-៦៤)ពីឆ្នាំ២០១៣-១៧ ................................................ ១៥

តារាង២.៣. រចនាសម្ព័ន្ធសេដ្ឋកិច្ច និងទីផ្សារការងារ នៅឆ្នាំ២០១៣ និង២០១៨ .................................................... ១៧

តារាង៣.១.បង្ហាញពី wage និង GDP ........................................................................................ ៣១

# បញ្ជីរូបភាព

រូបភាពទី១ អនុគមន៍ផលិតផលសរុបជាមួយ និងផលិតផលជាតិសរុប ............................................................៨
រូបភាពទី២ កត្តាដែលជះឥទ្ធិពលលើកំណើនសេដ្ឋកិច្ច ........................................................................១១

# បញ្ជីក្រាហ្វ


ក្រាប២.១. ការវិវត្តប្រាក់ឈ្នួលអប្បបរមារបស់ប្រទេសកម្ពុជាធៀបនឹងបណ្តាប្រទេសជាដៃគូប្រកួតប្រជែងពីឆ្នាំ ២០១៣ ដល់ ២០១៨ ........ ១៩

ក្រាហ្វ២.២. បង្ហាញពីនិន្នាការនៃកំណើនផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាចាប់ពីឆ្នាំ២០១៣ដល់២០១៩ ........ ២២

ក្រាហ្វ២.៣. បង្ហាញពីនិន្នាការនៃកំណើនផលិតផលក្នុងស្រុកម្នាក់ៗរបស់កម្ពុជាចាប់ពីឆ្នាំ២០១៣ដល់២០១៩ ........ ២៣

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជាជាប្រទេសមួយដែលស្ថិតនៅក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ក្នុងចំណោមប្រទេសក្រីក្រនានា នៅក្នុងពិភពលោក។ អ្វីដែលពីសេសនោះការអភិវឌ្ឍន៍ និងការកើនឡើងនៃកំណើនសេដ្ឋកិច្ចគួរអោយកត់សំគាល់មួយដែលត្រូវបានគេចាត់ទុកថា ជាប្រទេសមួយដែលមានការអភិវឌ្ឍន៍លឿនរហ័សមួយនៅក្នុងពិភពលោកជាមួយនឹងល្បឿនកំណើនសេដ្ឋកិច្ចក្នុងរង្វង់អត្រាប្រមាណជា៧%នៅក្នុងមួយឆ្នាំ។ បើយោងតាមការចុះផ្សាយរបស់ធនាគារ អភិវឌ្ឍន៍អាស៊ី( ADB) បានបង្ហាញថា នៅក្នុងឆ្នាំ២០១៨ កំណើនសេដ្ឋកិច្ចកម្ពុជាមានអាត្រា៧.៥% និងតាមការព្យាករណ៍សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៩នឹងមានការកើនឡើងប្រមាណជា៧%ទៀត។ ដោយស្ថិតក្រោមហេតុផលជាច្រើនប្រទេសកម្ពុជា ត្រូវបានគេវាយតម្លៃថា មានលក្ខណៈរឹងមាំ និងទទួលបានការរីកចម្រើនយ៉ាងឆាប់រហ័សនេះ គឺមានការចូលរួមពីកត្តាជាច្រើន ដូចជា ការនាំចេញរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុប និងប្រទេសនានាមាន ភាពនឹងនរ ការកម្រើកឡើងនៃសហគ្រាសធុនតូច និងមធ្យម ការវិនិយោគផ្ទាល់ពីបរទេស ការសម្រេចបាននូវគោលដៅទេសចរណ៍បរទេស ការរីកចម្រើនផ្នែកសំណង់ រួមទាំងការរក្សាស្ថេរភាពថ្លៃ និងអត្រាប្តូរប្រាក់ជាដើម។ ដោយហេតុផលទាំងនេះហើយបានធ្វើអោយវិស័យការងារនៅកម្ពុជាមានការកើនឡើងពីមួយថ្ងៃ ទៅមួយថ្ងៃ ពីមួយឆ្នាំទៅមួយឆ្នាំឥតឈប់ឈរ។

យោងតាមមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានបញ្ជាក់ថា បច្ចុប្បន្នកម្ពុជាបានឈានផុតពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្មមកពឹងផ្អែកលើវិស័យឧស្សាហកម្ម ព្រោះ វិស័យនេះចាប់ផ្តើមមានកំណើនខ្ពស់ហើយពាណិជ្ជករកម្ពុជាភាគច្រើនក៏កំពុងចាប់យកឳកាសលើការធ្វើពាណិជ្ជកម្មតាមបែបឧស្សាហកម្ម។ ដោយយើងអាចមើលឃើញពីសន្ទុះនៃការកើនឡើងនៃសហគ្រាសខ្នាតតូចនិងមធ្យមជាច្រើនកំពុងមមាញឹកក្នុងការកែច្នៃ ផលិតផល និងផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងក្រៅស្រុកផងដែរ ។

ដូច្នេះដោយយល់ឃើញថា សន្ទុះនៃវិស័យការងារមានការកើនឡើងខ្លាំងបែបនេះទើបខ្ញុំបាទបានលើកយកប្រធានបទក្នុងការស្រាវជ្រាវមួយនេះដោយលើកយកយកតែកំណើនសេដ្ឋកិច្ចរបស់កម្ពុជាដោយផ្អែកលើ ទំហំការងារការអភិវឌ្ឍន៍របស់រដ្ឋាភិបាលនៅលើវិស័យការងារនេះប៉ុណ្ណោះមកសិក្សា។

## ២. កម្មវត្ថុនៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទខាងលើនេះមានកម្មវត្ថុ៣យ៉ាងសំខាន់ដូចខាងក្រោម៖

- ការសិក្សាពីស្ថានភាព និងទំហំការងារនៅកម្ពុជា
- ការសិក្សាពីការយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍វិស័យការងាររបស់រដ្ឋាភិបាល
- ការសិក្សាពីទំហំការងារដែលជះឥទ្ធិពលលើកំណើនសេដ្ឋកិច្ចកម្ពុជា

## ៣. ចំណោទបញ្ហានៃការស្រាវជ្រាវ

តាមការបកស្រាយខាងលើយើងឃើញថាវិស័យការងារបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ និងជំរុញអោយមានកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ដូច្នេះយើងសូមលើកជាសំណួរថា តើវិស័យការងារបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា?

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

ដោយផ្អែកលើការស្រាវជ្រាវប្រធានបទ "ស្ថានភាព និងការអភិវឌ្ឍន៍វិស័យការងារដែលជះឥទ្ធិពលដល់កំណើនសេដ្ឋកិច្ចនៅកម្ពុជា" ខាងលើនេះបានផ្តល់នូវសារៈសំខាន់ដល់និស្សិតជាច្រើនដូចជា:

- ពង្រឹងការយល់ដឹងពីការអភិវឌ្ឍន៍របស់វិស័យការងារ
- សិក្សាពីគោលនយោបាយនៃការអភិវឌ្ឍន៍លើវិស័យការងាររបស់រដ្ឋាភិបាល

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះទំហំ និងដែនកំណត់នៃការស្រាវជ្រាវសារណាបញ្ចប់ការសិក្សានេះគឺ ត្រូវបានពិនិត្យមើលលើទិន្នន័យក្នុងរយៈពេល៧ឆ្នាំ ដោយផ្តោតលើការ ទំហំការងារ និង បម្រែបម្រួលសេដ្ឋកិច្ចកម្ពុជានៅចន្លោះឆ្នាំ២០១៣ ដល់ ឆ្នាំ ២០១៩។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីសិក្សាពីប្រធានបទ "**ការអភិវឌ្ឍន៍វិស័យការងារ ដែលជះឥទ្ធិពលដល់កំណើនសេដ្ឋកិច្ចកម្ពុជា** " បានប្រើវិធីសាស្ត្របរិមាណវិធី)quantity method) ក្នុងការស្រាវជ្រាវនិងប្រមូលទិន្នន័យដើម្បីផ្ទៀងផ្ទាត់ពីទំនាក់ទំនងរវាង កំណើនសេដ្ឋកិច្ច)Economic growth) និងប្រាក់បៀវត្តន៍នយោជិក (Wage) ៖

- តម្រូវទិន្នន័យ ៖ ប្រើទិន្នន័យទី២ )Secondary Data) មកធ្វើការវិភាគ

- ទីកន្លែងដែលអាចប្រមូលទិន្នន័យមានដូចជា
  - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  - ADB, World Bank
  - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - និង Website មួយចំនួនទៀតនៅលើប្រព័ន្ធអ៊ីធីណែត

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការរៀបចំស្រាវជ្រាវប្រធានបទស្តីពី "កំណើនសេដ្ឋកិច្ចផ្អែកលើសហគ្រាសខ្នាតតូចនិងមធ្យម បានចែកចេញជា៣ជំពូកសំខាន់ៗគឺ ៖ ជំពូកទី១ និយាយពីនិយមន័យ ក៏ដូចជាទ្រឹស្តីមួយចំនួនរបស់សេដ្ឋវិទូស្តីពី. ការអភិវឌ្ឍនសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច ជំពូកទី២ និយាយពីស្ថានភាពទូទៅរបស់ វិស័យការងារ ជំពូកទី៣ ធ្វើការវិភាគទិន្នន័យដើម្បីឈានដល់ការសិក្សាពីបញ្ហា ប្រឈមនិងដំណោះស្រាយផ្សេងៗ។

# ជំពូកទី១
# ការសិក្សាលើផ្នែកទ្រឹស្តី

# ជំពូកទី១ ការសិក្សាលើផ្នែកទ្រឹស្តី

## ១. ១. និយមន័យ

### ១.១.១. ការអភិវឌ្ឍន៍

ការអភិវឌ្ឍន៍ គឺជាដំណើរការនៃការធ្វើអោយប្រសើរឡើងនូវគុណភាពជីវិតក្នុងការរស់នៅ និងសមត្ថភាពរបស់ មនុស្សទាំងអស់ ដោយតាមរយៈការបង្កើននូវកម្រិតជីវភាពរស់នៅរបស់ប្រជាជន ការគោរព ការអោយតម្លៃការជឿ ទុកចិត្តលើខ្លួនឯង និងសេរីភាពរបស់មនុស្ស។

អភិវឌ្ឍន៍ គឺសំដៅលើចលនាវិវត្តពីស្ថានភាពមួយទៅស្ថានភាពមួយទៀតដែលល្អប្រសើរជាងមុន។ ការអភិវឌ្ឍ ជាដំណើរការនៃការប្រែក្លាយរចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងស្ថាប័នដែលបង្កលក្ខណៈ ងាយស្រួលឬអំណោយផលដល់ការធ្វើឲ្យសេដ្ឋកិច្ចរីកចម្រើនឲ្យកំណើនសេដ្ឋកិច្ចអាចបន្តបានយូរ ឬអាចនិយាយបានម៉្យាងទៀតថា ការអភិវឌ្ឍជាការបង្កលក្ខខណ្ឌឲ្យកំណើនសេដ្ឋកិច្ចមានចីរភាព។

ដូច្នេះយោងតាមអត្ថន័យយើងអាចឆ្លុះបញ្ចាំងពីដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចគឺជាចលនាវិវត្តន៍ ឬការកែប្រែសេដ្ឋកិច្ចសង្គមឲ្យមានភាពជឿនលឿនពីស្ថានភាពមួយទៅស្ថានភាពមួយទៀតដែលល្អប្រសើរនិងរីកចម្រើនជាងមុន។

តែក្នុងន័យសេដ្ឋកិច្ច ការអភិវឌ្ឍន៍ គឺទាក់ទងនឹងការកែលម្អក្នុងស្ថានភាពសេដ្ឋកិច្ចរបស់មនុស្ស គុណភាពរស់នៅ ល្អប្រសើរជាងមុន អត្រាកំណើននៃចំណូលក្នុងម្នាក់ៗ ឬផលិតផលជាតិក្នុងពលរដ្ឋម្នាក់ៗ ក៏ដូចជានៅក្នុងប្រទេស ទាំងមូល។ ការអភិវឌ្ឍន៍ ត្រូវបានលើកឡើងក្នុងទម្រង់កាត់បន្ថយ និងលុបបំបាត់នូវភាពក្រីក្រ វិសមភាព និងនិកម្មភាពជាដើម។

### ១.១.២. ការអភិវឌ្ឍន៍ជនបទ

ជនបទ គឺជាទីប្រជុំដែលនៅក្រៅក្រុង ឬជាតំបន់ដាច់ស្រយាលដែលឆ្ងាយពីទីក្រុង។ ការអភិវឌ្ឍជនបទគឺជាពាក្យទូលំទូលាយដែលផ្តោតលំខាន់លើសកម្មភាពសម្រាប់អភិវឌ្ឍន៍តំបន់នៅក្រៅប្រពន្ធ័សេដ្ឋកិច្ចទីក្រុង។
ការអភិវឌ្ឍជនបទគឺជា ដំណើរការនៃការលើកកម្ពស់គុណភាពនៃជីវិត និងសុខុមាលភាពសេដ្ឋកិច្ចរបស់ប្រជាជនដែលរស់នៅដាច់ ស្រយាល និងមានប្រជាជនតិចតួច។ ការអភិវឌ្ឍជនបទ គឺជាការធ្វើអោយប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធក៏ដូចជា មនុស្ស មុខរបរទាំងឡាយនៅតំបន់ដាច់ស្រយាលដែលគេហៅថា តំបន់ជនបទ។ ការអភិវឌ្ឍជនបទគឺជា បញ្ហាអន្តរវិស័យមួយយ៉ាងសំខាន់ផងដែរ រាប់បញ្ចូលតាំងពីបញ្ហាប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានការ

ធ្វើវិមជ្ឈការ និងរហូតដល់ការ បង្កើននិងការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ សេវាអប់រំនិងសេវាសុខាភិបាលដល់ប្រជាជននៅជនបទ។ ដូចនេះការ អភិវឌ្ឍជនបទគឺជាសមាសភាគមួយយ៉ាងសំខាន់សម្រាប់ប្រជាពលរដ្ឋ ។

### ១.១.៣. គោលបំណងនៃការអភិវឌ្ឍន៍

ពាក្យថា "ការអភិវឌ្ឍន៍" ជាដំណើរការនៃការធ្វើឲ្យប្រសើរឡើងខាងគុណភាពនៃការរស់នៅរបស់មនុស្សទាំងអស់ ដែលបង្ហាញតាមលក្ខខណ្ឌបីយ៉ាងគឺ ៖

១. ការធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាជន ដូចជាកម្រិតប្រាក់ចំណូល និងការដោះស្រាយបញ្ហា ប្រើប្រាស់នៃកំណើនម្រូវការរបស់ប្រជាជនអោយសមស្របតាមដំណើរការនៃទំនាក់ទំនងសេដ្ឋកិច្ច។

២. ការបង្កើតលក្ខខណ្ឌដែលនាំឲ្យការគោរពខ្លួនឯងរបស់មនុស្សជាតិដោយឆ្លងតាមរយៈស្ថាប័នសង្គម នយោបាយ និងស្ថាប័នសេដ្ឋកិច្ច។

៣. ការកើនឡើងនៃសេរីភាពក្នុងការប្រើប្រាស់មានទំហំកាន់តែធំដូចជា ប្រជាជនមានសិទ្ធិក្នុងការជ្រើសរើស ការប្រើប្រាស់ទំនិញ និងសេវាកម្មជាដើម។

ការអភិវឌ្ឍន៍ មានសមាសធាតុ ឬតម្លៃស្នូលចំនួនបីយ៉ាងត្រូវបានព្រមព្រៀងជាមួយមូលដ្ឋានគ្រឹះដែលពឹងផ្អែក លើគំនិត និងគោលការណ៍ប្រតិបត្តិដើម្បីយល់ដឹងពីអត្ថន័យខាងក្នុង។ តម្លៃស្នូលទាំងបីនោះគឺ ចីរភាព ការគោរពខ្លួនឯង និងសេរីភាពដែលបានបង្ហាញនូវគោលបំណងរួមរបស់បុគ្គលនីមួយៗ និងសង្គមនានា។ តម្លៃទាំងនោះទាក់ទងទៅ នឹងតម្រូវការមូលដ្ឋានរបស់មនុស្សដែលមាននៅក្នុងសង្គម និងវប្បធម៌នានាជាដរាប។

យើងអាចសន្និដ្ឋានថា ការអភិវឌ្ឍជាសច្ចភាព ជារូបវន្ត និងជាសភាពផ្លូវចិត្តដែលតាមរយៈការរួមផ្សំនៃដំណើរ ការសង្គម សេដ្ឋកិច្ច និងស្ថាប័ននេះឲ្យមានមធ្យោបាយនានាដើម្បីសម្រេចបាននូវជីវិតដ៏ល្អប្រសើរ។ បើទោះជា សមត្ថភាពនៃជីវិតល្អបែបណាក៏ដោយ យ៉ាងហោចណាស់ការអភិវឌ្ឍន៍ក្នុងសង្គមត្រូវមានគោលដៅបីដូចតទៅ ៖

១.ដើម្បីបង្កើនលទ្ធភាពអាចរកបាននិងដើម្បីពង្រឹងការបែងចែកទំនិញជីវិតជាមូលដ្ឋានដូចជាម្ហូបអាហារ ផ្ទះ សម្លៀង សុខភាព និងការថែរក្សាសុវត្ថិភាព។

២. ដើម្បីបង្កើនកម្រិតជីវភាពដែលរួមមានការផ្ដល់ឱកាសការងារច្រើន បង្កើនស្តង់ដាការអប់រំឲ្យប្រសើរជាងមុន យក ចិត្តទុកដាក់ខ្លាំងទៅលើតម្លៃវប្បធម៌មនុស្សធម៌ជាបន្ថែមទៅលើចំណូលខ្ពស់ជាងមុន ហើយធាតុទាំងនោះនឹង ជួយលើកកម្ពស់សុខុមាលភាពជាសម្ភារៈ ថែមទាំងជួយបង្កើតការគោរពជាតិ និងបុគ្គលមួយរូបៗផងដែរ។

៣. ដើម្បីពង្រីកលំដាប់នៃជម្រើសសេដ្ឋកិច្ច សង្គម ដែលបុគ្គលនីមួយៗ និងជាតិនានា គឺត្រូវប្រោនចេញពីភាពអវិជ្ជា និងទុក្ខសោកនានា។

## ១.១.៤. ទ្រឹស្តីសំខាន់ៗនៃការអភិវឌ្ឍន៍

ពាក្យថា អវឌ្ឍន៍ គឺជាពាក្យមួយដែលមានខ្លឹមសារ អត្ថន័យយ៉ាងទូលំទូលាយហើយមានទ្រឹស្តីនិងទស្សនៈជាច្រើនដែលត្រូវបានបង្កើតឡើងដោយអ្នកប្រាជ្ញសេដ្ឋកិច្ចដើម្បីពន្យល់បកស្រាយអំពី ការផ្លាស់ប្តូរដែលកើតមានឡើងនៅ ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងគោលបំណង ដើម្បីសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចនិងកំណើនទាំងមូល ហើយអត្ថន័យនៃពាក្យអភិវឌ្ឍន៍ត្រូវបានផ្លាស់ប្តូរទៅតាមសម័យកាលនីមួយៗតាមទស្សនៈយល់ឃើញរបស់អ្នកប្រាជ្ញនីមួយៗ ដើម្បីយល់ឲ្យកាន់តែច្បាស់លាស់និងស៊ីជម្រៅអំពីអត្ថន័យពាក្យ អភិវឌ្ឍន៍ យើងនឹងលើកយកទ្រឹស្តី សំខាន់ៗមួយចំនួនរបស់អ្នកប្រាជ្ញនីមួយៗមកពន្យល់បកស្រាយដូចខាងក្រោម ៖

ទ្រឹស្តីរបស់លោក **Walt Whitman Rostow**៖ បានបង្ហាញថា អភិវឌ្ឍន៍ គឺសំដៅទៅលើទំនាក់ទំនងនិងបម្លាស់ប្តូរពីជីវិតរស់នៅបែបប្រពៃណីយទៅកាន់ជីវិតរស់នៅបែបទំនើប ដែលមានរបៀបរៀបរយល្អនឹងអាចទស្សន៍ទាយជា មុននូវលទ្ធផលដែលគេនឹងទទួលបាននៅពេលអនាគត ។ លើសពីទៅទៀតលោកក៏បានលើកឡើងដែរផងថា ការអភិវឌ្ឍន៍ គឺទាក់ទងទៅនឹងការផ្លាស់ប្តូរផលិតកម្មកសិកម្មបែបប្រពៃណីទៅកាន់ផលិតកម្មដែលមានលក្ខណៈបែបវិទ្យាសាស្ត្រទំនើបដែលជាទូទៅត្រូវបានគេយកចិត្តទុកដាក់ខ្លាំងទៅលើផ្នែកឧស្សាហកម្ម។

ទ្រឹស្តីគំរូកំណើនរបស់លោក **Harrod-Domar**៖ យោងតាមគំរូរបស់លោក Harrod-Domar បានលើកឡើងថា គ្រប់បណ្តាសេដ្ឋកិច្ចទាំងអស់ចាំបាច់ត្រូវតែមានការ សន្សំដោយសមាមាត្រពិតប្រាកដនិងចំណូលជាតិដើម្បីយកទៅចំណាយលើទំនិញមូលធនដែលចាស់ៗខូចខាតដែល ត្រូវធ្វើការជួសជុលដូចជា អាគារ ឧបករណ៍ សម្ភារៈផ្សេងៗដែលបង់រំលោះ និងគ្រឿងបរិក្ខារជាដើម។ គំរូរបស់លោកត្រូវបានចែកចេញជាបីដំណាក់កាលនៅការបង្ហាញពីទំនាក់ទំនងនៃកំណើនសេដ្ឋកិច្ចដែលរួម មាន៖

- ទំនាក់ទំនងរវាងការសន្សំ និងចំណូលសរុប
- ទំនាក់ទំនងរវាងការវិនិយោគ និងបម្រែបម្រួលស្តុកមូលធន
- សន្សំជាតិសរុបត្រូវតែស្មើនឹងវិនិយោគសរុប។

តាមទស្សនៈរបស់សេដ្ឋកិច្ចវិទូខាងលើ គន្លឹះនៃការអភិវឌ្ឍគឺ ស្ថិតនៅលើការចេះប្រមូលមូលធនក្នុងស្រុកសរុប ដោយធ្វើឲ្យកម្រិតនៃការសន្សំនៅក្នុងស្រុកមានកម្រិតខ្ពស់និងការយកមូលធនបានពីការសន្សំដើម្បីយកទៅធ្វើការវិនិយោគទាំងអស់នោះជាលទ្ធផលគេនឹងទទួលបានអត្រាកំណើនកាន់តែខ្ពស់តាមនេះដែរ។ តាមទស្សនៈនេះមានន័យ ថា បើកាលណាអត្រាកំណើនសេដ្ឋកិច្ចកាន់តែខ្ពស់ការអភិវឌ្ឍនឹងមានសភាពកាន់តែខ្លាំងផងដែរ។

ទ្រឹស្តីរបស់លោក **Michael P.Todaro**៖ បើតាមទ្រឹស្តីលោក Michaol P.Todaro ចំពោះអត្ថន័យនៃពាក្យអភិវឌ្ឍន៍ លោកបានយល់ឃើញថាការ អភិវឌ្ឍអាចកើតមានឡើងនិងប្រកបដោយចីរភាព វាត្រូវចាប់ផ្តើមពីតំបន់

ជនបទ ជាពិសេសក្នុងវិស័យកសិកម្ម ហើយ ប្រទេសមួយអាចឈានដល់ការអភិវឌ្ឍបានយ៉ាងហោចណាស់ត្រូវមានចំណុចបីដូចខាងក្រោម ៖

- ការពន្លឿ (output) តាមរយៈការធ្វើកំណែទម្រង់ស្ថាប័ននិងបច្ចេកវិទ្យាដែលត្រូវបានរៀបចំឡើងដើម្បី បង្កើនផលិតភាពសម្រាប់កសិករតូចតាច។
- បង្កើនតម្រូវការក្នុងស្រុកសម្រាប់ផលិតផលកសិកម្មដែលមានប្រភពច្បាស់លាស់មកពីយុទ្ធសាស្ត្រ អភិវឌ្ឍន៍ការងារតំបន់ជាយក្រុង។
- សកម្មភាពអភិវឌ្ឍន៍ជនបទដើម្បីពង្រីកកម្លាំងពលកម្មនិងវិស័យផ្សេងៗដែលគាំទ្រដោយផ្ទាល់ ឬ ដោយប្រយោលពីស្ថាប័នពាក់ព័ន្ធ។

ទ្រឹស្តីរបស់លោក **Francois Peroux**៖ លោកFrancoisPeroux ជាអ្នកទ្រឹស្តីនៃការអភិវឌ្ឍន៍លើមនុស្សគាត់បានអោយនិយមន័យថាការអភិវឌ្ឍន៍គឺជាការចូលរួមនៃបំលាស់ប្តូរគំនិតចំពោះសង្គមរបស់ប្រជាជនមួយក្រុម ហើយក្នុងការរួមផ្សំនេះបានផ្តល់មកវិញនូវកំណើនសេដ្ឋកិច្ចផ្ទួនៗ និងស្ថិតថេរនៃផលិតផលសរុបរបស់ពួកគាត់។ ការអភិវឌ្ឍ គឺជាដំណើរការផ្លាស់ប្តូររចនាសម្ព័ន្ធសច្ច សង្គម វប្បធម៌ ដែលធ្វើអោយមានភាពសុក្រិត យុត្តិធម៌នៅក្នុងស្ថាប័ននិងរាជរដ្ឋាភិបាលនៅក្នុងការជំរុញអោយមានការអភិវឌ្ឍ ដើម្បីកាត់បន្ថយភាពក្រីក្រដែលធ្វើ អោយមានភាពមិនស្មើគ្នារវាងអ្នកមាននិងអ្នកក្រហើយលុបបំបាត់អក្ខរភាពដោយផ្តល់សេវាបណ្តុះបណ្តាលចំណេះដឹង ដល់ប្រជាជនទូទៅដើម្បីថែរក្សាបរិស្ថានឬធនធានធម្មជាតិឲ្យមានតុល្យភាព និងប្រទេសជាតិមានការរីកចម្រើនជា និរន្តរ៍។

តាមរយៈនិយមន័យនេះដើម្បីឲ្យមានការអភិវឌ្ឍគេចាំបាច់ត្រូវបង្កើតឲ្យមានការរីកចម្រើនខាងសេដ្ឋកិច្ចជាមុន សិនហើយផលទទួលបានពីការរីកចម្រើនសេដ្ឋកិច្ចនោះត្រូវបានគេយកទៅរៀបចំជាមូលដ្ឋានដើម្បី ពង្រីកកំណើនសេដ្ឋ កិច្ចហើយបែងចែកដោយសមធម៌ទៅលើគ្រប់ផ្នែកសេដ្ឋកិច្ចទាំងអស់។ ក្នុងនេះដែរ យើងឃើញថា ការដែលមាន កំណើនសេដ្ឋកិច្ចមិនមែនសុទ្ធតែមានការអភិវឌ្ឍនោះទេ តែផ្ទុយទៅវិញការអភិវឌ្ឍន៍ចាំបាច់ ត្រូវតែមានកំណើនសេដ្ឋកិច្ច។

## ១.២. ទំនាក់ទំនងរវាងវិស័យការងារ និងកំណើនសេដ្ឋកិច្ច

កំណើនសេដ្ឋកិច្ចរយៈពេលវែងប្រកបដោយនិរន្តរភាពបានមកពីការបង្កើនផលិតភាពកម្មករដែលមានន័យថាយើងអាចផលិត ផលិតផលមួយក្នុងបរិមាណដែលយើងត្រូវការ និងប្រកបដោយប្រសិទ្ធិភាព។ យើងអាចនិយាយម្យ៉ាងទៀតថា តើប្រជាជាតិរបស់អ្នកមានប្រសិទ្ធភាពប៉ុណ្ណាជាមួយពេលវេលានិងកម្មករ? ផលិតភាពការងារគឺជាតម្លៃដែលបុគ្គលិកម្នាក់ៗបង្កើតក្នុងមួយឯកតានៃការបញ្ចូលរបស់ខ្លួន។ វិធីងាយស្រួលបំផុតដើម្បីយល់ពីផលិតភាពការងារគឺស្រមៃថាកម្មករម្នាក់ដែលអាចធ្វើនំប៉័ង ១០ ដុំក្នុងមួយម៉ោងទល់នឹងកម្មករកម្មករដ៏ទៃទៀតដែលក្នុង

ម៉ោងតែមួយអាចធ្វើបានតែនំប៉័ងពីរដុំប៉ុណ្ណោះ។ នៅក្នុងឧទាហរណ៍ប្រឌិតនេះកម្មករទីមួយមានផលិតភាពច្រើនជាង ។ការមានផលិតភាពកាន់តែច្រើនមានន័យថាអ្នកអាចធ្វើបានច្រើនក្នុងរយៈពេលដូចគ្នា។

អត្រាកំណើននៃផលិតភាពសេដ្ឋកិច្ចត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងអត្រាកំណើននៃផលិតផលក្នុងស្រុកសរុបរបស់មនុស្សម្នាក់ទោះបីជាទាំងពីរមិនដូចគ្នាក៏ដោយ។ ឧទាហរណ៍ប្រសិនបើភាគរយនៃប្រជាជនដែលកាន់ការងារនៅក្នុងសេដ្ឋកិច្ចកើនឡើងនោះផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់នឹងកើនឡើងប៉ុន្តែផលិតភាពរបស់កម្មករម្នាក់ៗប្រហែលជាមិនត្រូវបានប៉ះពាល់ទេ។ក្នុងរយៈពេលវែងមធ្យោបាយតែមួយគត់ដែលផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់អាចកើនឡើងជាបន្តបន្ទាប់គឺប្រសិនបើផលិតភាពរបស់កម្មករជាមធ្យមកើនឡើង ឬប្រសិនបើមានការកើនឡើងនៃទុនបន្ថែម។




រូបភាពទី១ អនុគមន៍ផលិតផលសរុបជាមួយ និងផលិតផលជាតិសរុប (OpenStax, 2021)

### ១.២.១. ការកើនឡើងនៃសេដ្ឋកិច្ច

ជាទូទៅកំណើនសេដ្ឋកិច្ច(Economic growth)ត្រូវបានគេអោយនិយមន័យថា គឺជាកើនឡើងន បរិមាណផលិតផលនិងសេវាកម្មដែលបានផលិតឡើងដោយប្រទេសមួយក្នុងរយៈពេលកំណត់ណាមួយ។

កំណើនសេដ្ឋកិច្ចបណ្តាលមកពីតម្រូវការកើនឡើងនិងការកើនឡើងនូវសមត្ថភាពផលិតភាព។

ការកើនឡើងនៃតម្រូវការសរុប (AD) = (C + I + G + NX)

ដែល

C = ជាការចំណាយរបស់អតិថិជន

I = ការវិនិយោគ (ការវិនិយោគដើមទុនថេរ)

G = ការចំណាយរបស់រដ្ឋាភិបាល

NX = ការនាំចេញសុទ្ធ

កំណើនសេដ្ឋកិច្ចបណ្តាលមកពីកត្តាចំបងពីរគឺ:

- ការកើនឡើងនូវតម្រូវការសរុប (AD)
- ការកើនឡើងនៃការផ្គត់ផ្គង់សរុប (សមត្ថភាពផលិតភាព)

កត្តាដែលជះឥទ្ធិពលដល់ការកើនឡើងតម្រូវការសរុប AD

- អត្រាការប្រាក់ទាបជាងមុន : អត្រាការប្រាក់ទាបកាត់បន្ថយការចំណាយប្រាក់កម្ចីហើយដូច្នេះដែលើក ទឹកចិត្តដល់ការចំណាយរបស់អតិថិជននិងក្រុមហ៊ុនដើម្បីវិនិយោគ អត្រាការប្រាក់ទាបជាងនេះក៏ កាត់បន្ថយការបង់ប្រាក់កម្ចីមានទ្រព្យបញ្ចាំផងដែរដូច្នេះបង្កើនប្រាក់ចំណូលដែលអាចប្រើប្រាស់បាន របស់អ្នកប្រើប្រាស់។
- ការកើនឡើងប្រាក់ឈ្នួល ប្រាក់ឈ្នួលពិតប្រាកដខ្ពស់បង្កើនប្រាក់ចំណូលដែលអាចប្រើបាននិង លើកទឹកចិត្តដល់ការចំណាយរបស់អ្នកប្រើប្រាស់។
- បង្កើនការចំណាយរបស់រដ្ឋាភិបាល(G).ឧៈការវិនិយោគរបស់រដ្ឋាភិបាលលើការកសាងផ្លូវថ្មីបង្កើនការចំណាយលើផលប្រយោជន៍សុខុមាលភាពដែលបង្កើនប្រាក់ចំណូលដែលអាចប្រើប្រាស់បាន។
- ការវាយតំលៃ ការធ្លាក់ចុះតម្លៃនៃអត្រាប្តូរប្រាក់ ឧ. ធ្វើឱ្យការនាំចេញមានតម្លៃថោកនិងបង្កើន បរិមាណនៃការនាំចេញ(X)។ ការធ្លាក់ថ្លៃក៏ធ្វើឱ្យការនាំចូលមានតម្លៃថ្លៃកាត់បន្ថយបរិមាណនាំចូល និងធ្វើឱ្យទំនិញក្នុងស្រុកកាន់តែទាក់ទាញ។

- ភាពជឿជាក់ ៖ ការកើនឡើងនូវទំនុកចិត្តរបស់អតិថិជនជំរុញឱ្យគ្រួសារចំណាយដោយការសន្សំប្រាក់ ឬដកយកឥណទានផ្ទាល់ខ្លួនបន្ថែមទៀត។ វាអាចជួយឱ្យការចំណាយកាន់តែខ្ពស់ដូច្នេះជម្រុញការ ចំណាយ (C)ក៏កើនឡើង ។
- ពន្ធទាប ៖ ពន្ធលើប្រាក់ចំណូលទាបនឹងបង្កើនប្រាក់ចំណូលរបស់អ្នកប្រើប្រាស់និងបង្កើនការ ចំណាយរបស់អ្នកប្រើប្រាស់ (C) ។
- ការឡើងថ្លៃផ្ទះ ៖ ការឡើងថ្លៃផ្ទះបង្កើតផលទ្រព្យសម្បត្តិវិជ្ជមាន។ ម្ចាស់ផ្ទះដែលមើលឃើញពីការកើន ឡើងនៃតម្លៃផ្ទះរបស់ពួកគេនឹងមានឆន្ទៈចំណាយកាន់តែច្រើន (ផ្ទះសំរួលប្រសិនបើចាំបាច់)
- ស្ថេរភាពហិរញ្ញវត្ថុ ៖ ប្រសិនបើមានស្ថេរភាពហិរញ្ញវត្ថុហើយធនាគារមានឆន្ទៈផ្តល់ប្រាក់កម្ចីនោះក្រុម ហ៊ុននឹងកាន់តែមានឆន្ទៈក្នុងការវិនិយោគហើយការវិនិយោគនឹងបង្កើនតម្រូវការសរុប។
  ការកើនឡើងនៃការផ្គត់ផ្គង់សរុប (សមត្ថភាពផលិតភាព)
- បង្កើនដើមទុន ៖ ឧទាហរណ៍: ការវិនិយោគលើរោងចក្រថ្មីឬការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ប្រព័ន្ធទូរស័ព្ទនិងបច្ចេកវិទ្យាទំនើបមួយចំនួនទៀត។
- ការកើនឡើងនៃចំនួនប្រជាជនធ្វើការ តាមរយៈការធ្វើអន្តោប្រវេសន៍ឬអត្រាកំណើតខ្ពស់។
- បង្កើនផលិតភាពការងារតាមរយៈប្រព័ន្ធនៃការអប់រំនិងការបណ្តុះបណ្តាលប្រសើរជាងមុន ឬបច្ចេកវិទ្យាប្រសើរឡើង
- ស្វែងយល់ពីវត្ថុធាតុដើមថ្មីៗ៖ ឧទាហរណ៍: ការស្វែងរកប្រេងទុកបម្រុងដើម្បីបង្កើនទិន្នផលជាតិ
- ការកែលម្អបច្ចេកវិទ្យាដើម្បីកែលម្អផលិតភាពនៃដើមទុននិងការងារ។ ឧទាហរណ៍ អ្នកផលិតមីក្រូវ៉េវ និងអ៊ិនធើណេតបានចូលរួមចំណែកក្នុងកំណើនសេដ្ឋកិច្ច។ នៅពេលអនាគតកំណើនសេដ្ឋកិច្ចអាចម កពីបច្ចេកវិទ្យាថ្មីដូចជាបញ្ញាសិប្បនិម្មិត (AI) ដែលអាចឱ្យមនុស្សយន្តធ្វើការជំនួសកន្លែងការងាររបស់ មនុស្សបាន។

យើងអាចពិនិត្យតាមរយះគំនូសតាងខាងក្រោម :




ប្រភពដកស្រង់៖ (Pettinger, 2019)

## ១.២.២ ធាតុផ្សំសំខាន់ៗដែលធ្វើអោយមានកំណើនសេដ្ឋកិច្ច

### ១.២.២.១. ចំណូលពន្ធ

នៅក្នុងវិទ្យាសាស្ត្រសេដ្ឋកិច្ចគោលនយោបាយសារពើពន្ធគឺជាការប្រើការចំណាយ(Expenditure)និង ចំណូល (revenue) របស់រដ្ឋាភិបាលដើម្បីមានឥទ្ធិពលលើសេដ្ឋកិច្ច។ គោលនយោបាយសារពើពន្ធអាច ប្រៀបធៀបបានជាមួយ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច (macroeconomic policy) និងគោលនយោបាយ រូបិយវត្ថុ(monetary policy) ដែលព្យាយាមធ្វើឲ្យមានស្ថិរភាពសេដ្ឋកិច្ចដោយគ្រប់គ្រងអត្រាការប្រាក់ និង ការផ្គត់ផ្គង់រូបិយវត្ថុ(money supply)។ ឧបករណ៍សំខាន់ពីររបស់គោលនយោបាយសារពើពន្ធគឺការ ចំណាយរបស់រដ្ឋាភិបាល និងការកម្រិតពន្ធដារ។ ការប្រែប្រួលនៃកម្រិតនិងសមាសភាពផ្សេងៗនៃពន្ធដារនិង ការចំណាយរបស់រដ្ឋាភិបាល អាចមានឥទ្ធិពលផ្សេងៗលើសេដ្ឋកិច្ច៖

- តម្រូវការសរុប (aggregate demand) និងកម្រិតនៃសកម្មភាពសេដ្ឋកិច្ច
- ទម្រង់នៃការផ្តល់ធនធាន
- ការបែងចែកចំណូល

គោលនយោបាយសារពើពន្ធសំដៅលើការប្រើថវិការរដ្ឋាភិបាលដើម្បីមានឥទ្ធិពលលើចំនុចទីមួយខាង លើសកម្មភាពសេដ្ឋកិច្ច។

ដូចច្នេះ ការប្រមូលពន្ធគឺជាកត្តាសំខាន់មួយក្នុងការអភិវឌ្ឍប្រទេសដូចជា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ សាលារៀន មន្ទីពេទ្យ ចំណាយលើយោធា សន្តិសុខសង្គម ។ល។

### ១.២.២.២. ការវិនិយោគ

នៅពេលនំហូរនៃការវិនិយោគនៅប្រទេសមួយកាន់តែច្រើន ធ្វើអោយប្រទេសនោះមានលទ្ធភាពក្នុង ការអភិវឌ្ឍន៍ប្រទេសកាន់តែច្រើនដូចគ្នា។ ការវិនិយោគនឹងបង្កើនការផលិតនូវផលិតផល និងសេវាកម្ម បន្ថែមក្នុងស្រុក បង្កើតនូវការងារជាច្រើនដល់ប្រជាពលរដ្ឋក្នុងប្រទេសនោះ ដែលជាកត្តាមួយក្នុងការកាត់ បន្ថយភាពក្រីក្រ និងជម្រុញកំណើនផលិតផលក្នុងស្រុកសរុបកាន់តែច្រើន។

### ១.២.២.៣. ពាណិជ្ជកម្ម

ការធ្វើពាណិជ្ជកម្ម គឺជាចំណុចសំខាន់មួយដែរ ដែលផលិតផល និងសេវាកម្មនៅក្នុងស្រុកត្រូវបាន ដោះដូរជាមួយទំនិញ ឬសេវាកម្មពីខាងក្រៅដើម្បីបំពេញតម្រូវការ ហើយក៏ពង្រីកទីផ្សារផលិតផល និងសេវា កម្មដែលផលិតបានដូចគ្នា។ ក្នុងនោះក៏មានការរួមបញ្ចូលទាំងការដោះដូរកម្លាំងពលកម្ម និងបច្ចេកវិទ្យាធ្វើអោយបរិយាកាសដំណើរការសេដ្ឋកិច្ច កាន់តែសំបូរបែប និងមានភាពនវានុវត្តន៍។

# ជំពូកទី២

# ស្ថានភាពទូទៅនៃវិស័យ

# ការងារនិង សេដ្ឋកិច្ចកម្ពុជា

# ជំពូកទី២ ស្ថានភាពទូទៅនៃវិស័យការងារ

## ២.១. ស្ថានភាពទូទៅនៃវិស័យការងារ

### ២.១.១. ការផ្គត់ផ្គង់កំលាំងពលកម្ម

នៅចន្លោះឆ្នាំ២០១៣ ទៅ២០១៨ ចំនួនប្រជាជនសរុបមានចំនួនកើនឡើងពី ១៥លាននាក់ ទៅ ១៦,២ លាននាក់ ឬកើនឡើង ៣,២% ជាមធ្យមក្នុង១ឆ្នាំ ដែលក្នុងនោះអាត្រាកើនឡើងរបស់មនុស្សប្រុសបានកើនឡើង ២,៦% ខ្ពស់ជាងមនុស្សស្រីដែលមានអាត្រា ២,០%។ ប្រជាជនដែលកើនលើងលឿនជាងអាត្រាកំនើនសរុប គឺស្ថិត នៅក្នុងក្រុមអាយុ ២៥ ដល់ ៣៤, ៣៥ ដល់ ៤៤, និង ៥៥ ដល់ ៦៤។ ទន្ទឹមនេះចំនួនប្រជាជនដែលមានអាយុ ១៥ ដល់ ២៤ បានថយចុះចំនួន ០,២% ជាមធ្យមក្នុង១ឆ្នាំដែលបណ្តាលមលពីការថយចុះចំនួនក្នុងក្រុមមនុស្សស្រីក្នុង ក្រុមអាយុនេះ ៥,៣% ក្នុង១ឆ្នាំ។ នៅក្នុងចន្លោះឆ្នាំដូចគ្នានេះប្រជាជនដែលកើនឡើងច្រើនជាងគេគឺ ស្ថិតនៅក្នុងក្រុម អាយុ ២៥ ដល់ ៣៤ មានប្រមាណ ៩៨ពាន់នាក់ក្នុង១ឆ្នាំ ឬស្មើនឹង ៣៥,១% នៃចំនួនប្រជាជនសរុប។

នៅក្នុងឆ្នាំ២០១៨ ប្រជាជនកម្ពុជាភាគច្រើនមានអាយុចាប់ពី០ ទៅ ១៤ឆ្នាំ ដែលមានចំនួន ៤,៦លាននាក់ ឬស្មើនឹង ២៨,៥% នៃចំនួនប្រចាជនសរុប។ ប្រមាណ៥០,៨% នៃចំនួនប្រជាជនសរុបគឺ ជាមនុស្សស្រី និង៤៩,២% ជាមនុស្សប្រុស។ ២០២៣ ចំនួនប្រជាជនសរុបនឹងកើនឡើងដល់ ១៧,១លាននាក់ ដែលក្នុងនោះប្រជាជន ដែល មានអាយុពី ០ ទៅ ១៤ឆ្នាំ មានចំនួន ២៧,៧% នៃចំនួនកំណើនប្រជាជនសរុប។

## តារាង២. ១. ចំនួនប្រជាជនសរុបនៅតាមក្រុមមនុស្ស នៅចន្លោះឆ្នាំ២០១៣ និង ឆ្នាំ ២០១៨

| ក្រុមអាយុ | ចំនួនប្រជាជន (ពាន់នាក់) | | ការប្រែប្រួលជាមធ្យមក្នុង១ឆ្នាំ(២០១៣-១៨) | |
|---|---|---|---|---|
| | ២០១៣ | ២០១៨ | បរិមាណ(%)នៃប្រជាជនសរុប | អាត្រាកំណើន(%) |
| | សរុប | សរុប | សរុប | សរុប |
| ០-១៤ | ៤,៣១៨ | ៤,៥៧៩ | ១៨.៧ | ១.៥ |
| ១៥-២៤ | ៣,២០៨ | ៣,១៨១ | -២ | -០.២ |
| ២៥-៣៤ | ២,៥០៥ | ២,៩៩៤ | ៣៥.១ | ៤.៦ |
| ៣៥-៤៤ | ១,៦១២ | ១,៩១៧ | ២១.៩ | ៤.៤ |
| ៤៤-៥៤ | ១,៤១១ | ១,៥៤១ | ៩.៣ | ២.២ |
| ៥៥-៦៤ | ៨៦៩ | ១,០៥៩ | ១៣.៧ | ៥.១ |
| ៦៥+ | ៧៥៥ | ៧៩៩ | ៣.២ | ១.៤ |
| ប្រជាជនសរុប | ៧១២២ | ៧៥៥៦ | ១០០ | ២.៣ |

ប្រភព៖ (http://www.mlvt.gov.kh/, 2021)

### ២.១.២.ប្រជាជនស្ថិតក្នុងវ័យធ្វើការ

នៅចន្លោះពី ឆ្នាំ២០១៣-២០១៨ ក្រុមប្រជាជនដែលស្ថិតក្នុងវ័យធ្វើការ (១៥-៦៤ឆ្នាំ) បានកើនឡើងពី ៩៦ លាននាក់ ទៅ ១០៧លាននាក់ ឬ ២៣%ជាមធ្យមក្នុងមួយឆ្នាំ ដែលក្នុងនោះ អត្រាកំណើនរបស់មនុស្ស ប្រុស (៣,៣%) ខ្ពស់ជាងមនុស្សស្រី(២១%)។ ជិតពាក់កណ្តាលនៃចំនួនកើនឡើងរបស់ប្រជាជនដែលស្ថិត ក្នុងវ័យធ្វើការសរុប (៤៥,0%) គឺស្ថិតនៅក្នុងក្រុមអាយុ២៥ ៣៤ឆ្នាំ (តារាង ២១)។ នៅឆ្នាំ២០១៨ ភាគច្រើន នៃប្រជាជនស្ថិតក្នុងវ័យធ្វើការមានអាយុពី១៥ទៅ៣៤ឆ្នាំ ដែលក្នុងនោះ ២៩,៧% មានអាយុពី១៥ ទៅ ២៤ឆ្នាំ និង(២៨,0%) មានអាយុពី២៥ ទៅ៣៤ឆ្នាំ ហើយនៅក្នុងឆ្នាំ២០២៣ ចំនួនប្រជាជនស្ថិតក្នុងវ័យធ្វើការនឹងកើនដល់ ប្រមាណជា ១១,៤លាននាក់ ពោលគឺកើនឡើង១៤៤ពាន់នាក់ ក្នុងមួយឆ្នាំចន្លោះពីឆ្នាំ២០១៩-២០២៣។

## ២.១.៣.កំរិតអប់រំនៃប្រជាជនស្ថិតក្នុងវ័យធ្វើការ

នៅចន្លោះពីឆ្នាំ២០១៣ ទៅ ២០១៧ ការអប់រំរបស់អ្នកស្ថិតក្នុងវ័យធ្វើការបានកើនឡើងគួរឱ្យកត់សម្គាល់ ដោយ ចំនួនអ្នកដែលទទួលបានការអប់រំកម្រិតឧត្តមសិក្សា និងមធ្យមសិក្សាទុតិយភូមិ បានកើនឡើងទ្វេដង (តារាង ២.២)។ ទន្ទឹមគ្នានេះអត្រាអ្នកមានការអប់រំតិចជាងថ្នាក់បឋមសិក្សាបានថយចុះប្រមាណជា-៤,៩ភាគរយ ហើយអត្រាអ្នកដែលទទួលមានការអប់រំខ្ពស់ជាងថ្នាក់មធ្យមសិក្សាទុតិយភូមិបានកើនឡើង ៦,១ពិន្ទុភាគរយ ក្នុង ចន្លោះឆ្នាំដូចគ្នា។ ក្នុងរយៈពេលដូចគ្នានេះ យើងក៏សង្កេតឃើញមានការកើនឡើងនៃកម្រិតអប់រំរបស់មនុស្ស ស្រីនៅកម្រិតឧត្តមសិក្សា និងមធ្យមសិក្សាទុតិយភូមិ ជាមួយនឹងអត្រាខ្ពស់ជាងមនុស្សប្រុស។ ទោះបីជាមានវឌ្ឍនភាពដូចខាងលើ ភាគច្រើននៃប្រជាជនស្ថិតក្នុងវ័យធ្វើការ គឺនៅមានកម្រិតអប់រំ និងជំនាញកម្រិតទាប។ ជាក់ស្តែងនៅឆ្នាំ២០១៧ ប្រមាណជា៤,៣លាននាក់ ឬ ៤១,៨% មិនបានចូលរៀន ឬមិនបានបញ្ចប់ថ្នាក់បឋមសិក្សា ខណៈអ្នកទទួលបានការអប់រំ ខ្ពស់ជាងមធ្យមសិក្សាទុតិយភូមិមានចំនួន ១,៥លាននាក់ ឬ ១៤,៤% តែប៉ុណ្ណោះ។

**តារាង២. ២. កម្រិតអប់រំរបស់ប្រជាជនស្ថិតក្នុងវ័យធ្វើការ(១៤-៦៤)ពីឆ្នាំ២០១៣-១៧**

| ក្រុមអាយុ | ចំនួនប្រជាជន (ពាន់នាក់) | | ការប្រែប្រួលជាមធ្យមក្នុង១ឆ្នាំ(២០១៣-១៧) | |
|---|---|---|---|---|
| | ២០១៣ | ២០១៧ | បរិមាណ(%)នៃប្រជាជនសរុប | អាត្រាកំណើន(%) |
| | សរុប | សរុប | សរុប | សរុប |
| ឧត្តមសិក្សា | ៣២៦ | ៦៦៥ | ៤១.៧ | ១៩.៥ |
| មធ្យមសិក្សាទុតិយភូមិ | ៤៦៦ | ៨៣៤ | ៤៥.៣ | ១៥.៧ |
| មធ្យមសិក្សាបឋមភូមិ | ១៧៧៩ | ១៨៦០ | ១០ | ១.១ |
| បឋមសិក្សា | ២៥៦១ | ២៧០៨ | ១៨.១ | ១.៤ |
| មិនបញ្ចប់បឋមសិក្សា | ៣២១៦ | ៣១៣១ | -១០.៤ | ០.៧ |
| មិនបានរៀន | ១២៥៧ | ១២១៨ | -៤.៩ | ០.៨ |
| ប្រជាជនសរុប | ៩៦០៤ | ១០៤១៦ | ១០០ | ២.០ |

ប្រភព៖ (http://www.mlvt.gov.kh/, 2021)

## ២.១.៤.ស្ថានភាពសេដ្ឋកិច្ច និងការងារ

កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រមាណជា៧,០%នៅក្នុងចន្លោះពី ឆ្នាំ២០១៣ ទៅ២០១៨ ទោះបីស្ថានភាពសេដ្ឋកិច្ចសកលលោក មានលក្ខណៈមិនប្រាកដប្រជា ហើយប្រទេសមួយចំនួនកំពុងជួបប្រទះបញ្ហាវិបត្តិបំណុលសាធារណៈ។ ក្នុងរយៈពេលដូចគ្នានេះ ចំនួនអ្នកមានការងារធ្វើ(១៥ឆ្នាំ+) បានកើនឡើងពី ៨៣ លាននាក់នៅឆ្នាំ២០១៣ ទៅ ៥,៦លាននាក់ នៅឆ្នាំ២០១៨ ពោលគឺកើនឡើង ២៩% ជាមធ្យមក្នុងមួយឆ្នាំ ដែល ខ្ពស់ជាងអាត្រាកំណើនរបស់ប្រជាជនដែលស្ថិតក្នុងវ័យធ្វើការ(២,៧%ជាមធ្យមក្នុងមួយឆ្នាំ)។ ជាលទ្ធផល អនុបាតអ្នកមានការងារទៅនឹងប្រជាជន (១៥ឆ្នាំ+) ដែលបង្ហាញពីលទ្ធភាពសេដ្ឋកិច្ចក្នុងការ ផ្តល់ការងារដល់ប្រជាជនដែលស្ថិតនៅក្នុងវ័យធ្វើការ ឬផ្តល់ការងារដល់អ្នកចង់ស្វែងរកការងារ រក្សាបានអត្រាថេរក្នុងរង្វង់ ៨០,៦% ក្នុងរយៈពេលដូចគ្នានេះ។ ប៉ុន្តែ អនុបាតនេះមានអត្រាខ្ពស់សម្រាប់បុរស ( ៨៦,៤%) ជាងស្ត្រី (៧៥,២%)។ ទន្ទឹមនឹងនេះ អត្រានិកម្មភាព (១៥ឆ្នាំ+) ស្ថិតនៅក្នុង អត្រាមួយទាបជាង ១% ប៉ុន្តែអត្រានិកម្មភាព របស់យុវជន (១៥-២៤ឆ្នាំ) ជាពិសេសយុវជនជាបុរសមានកម្រិតខ្ពស់ជាងអត្រានិកម្មភាពទូទៅ (១៥ឆ្នាំ+)។ ក្នុងចន្លោះឆ្នាំដូចគ្នានេះ អត្រាចូលរួមកម្លាំងពលកម្មដែលវាស់ពីអត្រាប្រជាជនសកម្មនៅក្នុងប្រទេស បានរក្សាកម្រិត មួយថេរ និងខ្ពស់ប្រមាណជា ៨១,០% ដែលខ្ពស់ជាងអត្រាជាមធ្យមរបស់អាស៊ានប្រមាណជា ៦៨,១%។ អត្រាចូល រួមរបស់មនុស្សប្រុសខ្ពស់ជាងមនុស្សស្រីប្រមាណជា ១១,៣ពិន្ទុភាគរយ ក្នុងចន្លោះពីឆ្នាំ២០១៣-២០១៨។

## ២.១.៥.ស្ថានភាពការងារនៅតាមវិស័យ

កំណើនសេដ្ឋកិច្ចនាពេលកន្លងមក មិនត្រឹមតែធ្វើឱ្យមានការប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច ហើយក៏បានជះឥទ្ធិពលទៅលើរចនាសម្ព័ន្ធទីផ្សារការងារផងដែរ។ នៅចន្លោះឆ្នាំ២០១៣ ២០១៨ ផ.ស.ស របស់វិស័យកសិកម្មបានកើនឡើង១,១%ក្នុងមួយឆ្នាំខណៈចំនួនការងារក្នុងវិស័យនេះបានថយចុះ ៣,២%ក្នុងមួយឆ្នាំ។ ជាលទ្ធផលបរិមាណភាគនៃអ្នកធ្វើការនៅក្នុងវិស័យកសិកម្មបានថយចុះពី ៤៩,៥% នៅក្នុងឆ្នាំ២០១៣ មកត្រឹម ៣៦,៤% នៅក្នុងឆ្នាំ២០១៨។ ជាមួយនឹងអត្រាកំណើន ផ.ស.ស ១០,៤% ក្នុងមួយឆ្នាំ វិស័យឧស្សាហកម្មបានបង្កើតការងារបន្ថែមសម្រាប់ប្រជាជនកម្ពុជា ប្រមាណជា ៨៩៤ពាន់នាក់ ក្នុងចន្លោះឆ្នាំដូចគ្នានេះ ហើយបរិមាណភាគនៃអ្នកធ្វើការនៅក្នុងវិស័យឧស្សាហកម្មបានកើនឡើងពី ១៩,៣% ទៅ ២៦,១%។ ទន្ទឹមនឹងនេះ ផ.ស.ស របស់វិស័យ សេវាកម្មបានរក្សាកំណើនវិជ្ជមានក្នុងរង្វង់ ៧,៣% ក្នុងមួយឆ្នាំ និងបានបង្កើតការងារបន្ថែមប្រមាណ ១លាននាក់ ហើយបរិមាណភាគអ្នកមានការងារធ្វើនៅក្នុងវិស័យនេះបានកើនឡើងពី ៣១,២% ទៅ ៣៧,៥% នៅក្នុងចន្លោះពីឆ្នាំ ២០១៣ ដល់ ២០១៨។

## តារាង២.៣. រចនាសម្ព័ន្ធសេដ្ឋកិច្ច និងទីផ្សារការងារ នៅឆ្នាំ២០១៣ និង២០១៨

| វិស័យ | ផលិតផលក្នុងស្រុកសរុប (ថ្លៃថេរនៅឆ្នាំ២០០០) | | | ការងារ(១៥ឆ្នាំ+) | | |
|---|---|---|---|---|---|---|
| | បរិមាណ(%) | | អាត្រាកំណើន(%) | បរិមាណ(%) | | អាត្រាកំណើន(%) |
| | ២០១៣ | ២០១៨ | (ក្នុង១ឆ្នាំ) | ២០១៣ | ២០១៨ | (ក្នុង១ឆ្នាំ) |
| កសិកម្ម | ២៤.២ | ១៨.២ | ១.១ | ៤៩.៥ | ៣៦.៤ | -៣.២ |
| ឧស្សាហកម្ម | ២៩.៩ | ៣៤.៩ | ១០.៤ | ១៩.៣ | ២៦.១ | ៩.៣ |
| សេវាកម្ម | ៣៩.០ | ៣៩.៦ | ៧.៣ | ៣១.២ | ៣៧.៥ | ៦.៨ |
| ប្រជាជនសរុប | ១០០ | ១០០ | ៧.០ | ១០០ | ១០០ | ២.៩ |

ប្រភព៖ (http://www.mlvt.gov.kh/, 2021)

ជាលទ្ធផល យើងក៏សង្កេតឃើញមានវិសមភាពរវាងបរិមាណភាគនៃ ផ.ស.ស ទៅនឹងបរិមាណភាគនៃកម្លាំងពលកម្មតាមវិស័យដែលនេះបានឆ្លុះបញ្ចាំងពីកម្រិតខុសគ្នានៃផលិតភាពការងារ។ ជាក់ស្តែងនៅឆ្នាំ២០១៨ វិស័យកសិកម្មបានចូលរួមចំណែកក្នុង ផ.ស.ស ត្រឹមតែ ១៨,២% តែវិស័យនេះបានស្រូបយកកម្លាំងពលកម្មរហូតដល់ ៣៦,៨%។ ផ្ទុយមកវិញ វិស័យឧស្សាហកម្មដែលចូលរួមចំណែកក្នុង ផ.ស.ស ប្រមាណជា ៣៤,៩% ប្រើប្រាស់កម្លាំងពលកម្មប្រមាណជា ២៦,១% ខណៈដែលវិស័យសេវាកម្មដែលចូលរួមចំណែកក្នុង ផ.ស.ស ប្រមាណ ជា ៣៩,៦% បានប្រើប្រាស់កម្លាំងពលកម្ម ៣៧,៥% (តារាង២.៣)។ នេះបានបង្ហាញថា វិស័យកសិកម្មគឺជា វិស័យដែលមានផលិតភាពទាបជាងគេ ធៀបទៅនឹងវិស័យឧស្សាហកម្ម និងសេវាកម្ម។

ក្នុងចំណោមការងារដែលបានកើនឡើងបន្ថែមចំនួន ១៣លានកន្លែង ក្នុងចន្លោះឆ្នាំ២០១៣-២០១៨ ភាគច្រើនស្ថិតនៅក្នុងវិស័យឧស្សាហកម្ម (៦៩,៨%នៃចំនួនការងារដែលបានបង្កើត) និងសេវាកម្ម (៧៨,៥%) ចំណែកការងារនៅក្នុងវិស័យកសិកម្មបានថយចុះ(៤៥,២%)។ ការងារក្នុងវិស័យកសិកម្ម មានការធ្លាក់ចុះទាំង បរិមាណភាគរយ និងចំនួនដែលនេះបានឆ្លុះបញ្ចាំងពីបំលាស់កម្លាំងពលកម្មពីវិស័យកសិកម្មដែលមានផលិតភាព ទាប ទៅរកវិស័យទំនើបផ្សេងទៀតដែលមានផលិតភាពខ្ពស់ រួមមាន វិស័យឧស្សាហកម្ម និងសេវាកម្ម។ ជារួមនៅចន្លោះពីឆ្នាំ ២០១៣ ទៅ ២០១៨ យើងបានកត់សម្គាល់និន្នាការតម្រូវការការងារតាមអនុវិស័យ (តារាងទី២,៣) ដូចខាងក្រោម

- អនុវិស័យដែលបង្កើតការងារច្រើនជាងគេគឺ សំណង់ (៧៨ពាន់នាក់ ក្នុងមួយឆ្នាំ) និងទី២ វាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង(៧៣ពាន់នាក់ ក្នុងមួយឆ្នាំ)
- អនុវិស័យដែលមានអត្រាកំណើនការងារលឿន (អត្រាកំណើន ២ខ្ទង់ ក្នុងមួយឆ្នាំ) មាន+ ហិរញ្ញវត្ថុ និងធានារ៉ាប់រង (២២,៦%) ផលិតផលជ័រកៅស៊ូ និងប្លាស្ទិក (២១,១%) កម្មន្តសាលផ្សេងៗ (១៤,៩%) អចលនទ្រព្យ និងសេវាគាំទ្រអាជីវកម្ម (១៤, ៤%) និងសំណង់ (១២, ៩%)
- អនុវិស័យដែលមានចំនួនការងារធ្លាក់ចុះមាន+ ដំណាំ, រុក្ខាប្រមាញ់, ការជីករ៉ែ និងការនេសាទ
- នៅឆ្នាំ២០១៨ អនុវិស័យ៤ ដែលមានអ្នកធ្វើការច្រើនជាងគេគឺ៖ ដំណាំ(២៥,៤%) ពាណិជ្ជកម្មលក់ដុំ និងរាយ (១២,៨%) វាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង(១១,៤%) និងសំណង់ (៨,៩%)។

## ២.១.៦. ការប្រែប្រួលប្រាក់ឈ្នួល

នៅក្នុងរយៈពេលដូចគ្នាប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង បានកើនឡើងជាលំដាប់ ពោលកើនឡើងពី ១០០ដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ២០១៤ ដល់ ១៧០ ដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ២០១៨។ ហើយសម្រាប់ឆ្នាំ២០១៩ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតក្នុងវិស័យនេះកើនឡើងដល់១៨២ដុល្លារសហរដ្ឋអាមេរិក។ បើធ្វើការប្រៀបធៀបជាមួយបណ្តាប្រទេសដែលមានស្ថានភាព សេដ្ឋកិច្ច-សង្គមប្រហាក់ប្រហែលគ្នា និងជាដៃគូប្រកួតប្រជែងចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ ២០១៨នេះ ប្រាក់ឈ្នួលអប្បបរមានៅកម្ពុ ជាបានកើនឡើងជាលំដាប់ប្រមាណជា ១៦,៣%ជាមធ្យមក្នុងមួយឆ្នាំ ឬកើនឡើងជិត ២ដង ខណៈដែលប្រទេស វៀតណាម ភូមា និងបង់ក្លាដែស បានដំឡើងប្រាក់ឈ្នួលអប្បបរមារបស់ខ្លួនក្នុងអត្រាកំណើនទាប ឬមិន ទៀងទាត់ (រូបភាពទី ២.១)។ កម្រិតនៃប្រាក់ឈ្នួលអប្បបរមានេះ បានដើរតួជាប្រាក់ឈ្នួលយោងសម្រាប់ វិស័យកម្មន្តសាលផ្សេងទៀតក្នុងការចរចាប្រាក់ឈ្នួល។ ទន្ទឹមនឹងនេះចំនួនប្រាក់ឈ្នួលទូទៅក៏មានការកើនឡើងគ្រប់វិស័យ ដោយសារកំណើនការងារនៅក្នុងស្រុក និងទេសន្តរប្រវេសន៍ការងារ ទៅប្រទេសដែលមានការអភិវឌ្ឍ សង្គម-សេដ្ឋកិច្ច និងប្រាក់ឈ្នួលខ្ពស់ជាងកម្ពុជា។

ក្រាប២.១.ការវិវត្តប្រាក់ឈ្នួលអប្បបរមារបស់ប្រទេសកម្ពុជាធៀបនឹងបណ្តាប្រទេសជាដៃគូប្រកួតប្រជែងពីឆ្នាំ ២០១៣ ដល់ ២០១៨




ប្រភព៖ក្រសួងការងារ និងបណ្តុះនវិជ្ជាជីវៈ(http://www.mlvt.gov.kh/index.php/)

## ២.១.៧. ការប្រែប្រួលផលិតភាពការងារ

ទោះបីជាកន្លងមក សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនខ្ពស់ក្នុងរង្វង់អត្រា៧,០% តែកំណើនសេដ្ឋកិច្ច នេះបានត្រូវបានជំរុញដោយកំណើនកត្តាផលិតកម្ម ជាពិសេសកត្តាកម្លាំងពលកម្ម។ យោងតាមរបាយការណ៍ នៅក្នុងឆ្នាំ ២០១៨ របស់អង្គការផលិតភាពអាស៊ី (APO) កំណើនផលិតការងារ ក្នុងចន្លោះពីឆ្នាំ២០១០-២០១៦ នេះ កម្ពុជាសម្រេចបាននូវកំណើនប្រមាណជា ៤,៤%ជាមធ្យមក្នុងមួយឆ្នាំ ដែលក្នុងនោះ ៩៥% ត្រូវបានរួមចំណែក ដោយកំណើនមូលធនធៀបនឹងពលកម្ម និង៥% ដោយកំណើនផលិតភាពសរុប។ ទន្ទឹមនឹងនេះកំណើនផលិត ភាពនេះក៏ត្រូវបានជំរុញ ដោយសារការបង្វែរកម្លាំងពលកម្មចំនួនដ៏ច្រើនចេញពីវិស័យកសិកម្ម ដែលមានផលិតភាព ទាបចូលមកក្នុងវិស័យឧស្សាហកម្មដែលមានផលិតភាពខ្ពស់ជាង (ដូចបានបង្ហាញខាងលើ) ដែលនឹងមិនអាចរក្សាបានចីរភាពក្នុងរយៈពេលវែង។ បើប្រៀបធៀបនឹងប្រទេសសិង្ហបុរី ដែលជាប្រទេសមានផលិតភាពខ្ពស់ជាងគេ នៅលើពិភពលោក នាឆ្នាំ ២០១៥ ផលិតភាពកម្ពុជាក្នុងមនុស្សម្នាក់មានកម្រិតទាបជាងគេនៅក្នុងអាស៊ី ដោយមានកម្រិតត្រឹមតែ ៤,៧% ខណៈពេលដែលប្រទេសបង់ក្លាដេសមានកម្រិត៦,២% វៀតណាម(១០,២%) មីយ៉ាន់ម៉ា (៨,០%) ឡាវ(៨,៧%) ភីលីពីន(១៤,២%) ឥណ្ឌូនេស៊ី (១៨,៩%) ថៃ(២១,៥%) និងម៉ាឡេស៊ី (៤២,៣%)។

## ២.១.៨.ស្ថានភាពទេសន្តរប្រវេសន៍ការងារ

ស្របជាមួយនឹងការបង្កើតការងារក្នុងប្រទេស ឱកាសការងារនៅក្រៅប្រទេសក៏ជាប្រភពការងារមួយដ៏សំខាន់សម្រាប់កម្លាំងពលកម្មកម្ពុជា។ ចន្លោះពី ឆ្នាំ២០១៣-២០១៨ ចំនួនពលករទេសន្តរប្រវេសន៍បានកើន ឡើងពីប្រមាណជា ៥០៧ ៦៦៩នាក់ ដែលក្នុងនោះទៅប្រទេសថៃមានការកើនឡើង ៤៩៤ ៧៤០នាក់ ប្រទេសជប៉ុនកើនឡើង ៦ ៨៩៥នាក់ សាធារណរដ្ឋកូរ៉េកើនឡើង ២០ ២៧២នាក់ សិង្ហបុរីកើនឡើង ៧២០នាក់ តំបន់រដ្ឋបាលពិសេសហុងកុងកើនឡើង ៥៤នាក់ អារ៉ាប៊ីសាអូឌីតកើនឡើង ១៦នាក់ និងប្រទេសម៉ាឡេស៊ីថយចុះ ១៥នាក់។ នៅឆ្នាំ ២០១៨ បើយើងពិនិត្យទៅតាមចំនួនអ្នកធ្វើការងារនៅក្រៅប្រទេសសរុប ប្រមាណ ១,២លាន នាក់ ប្រមាណជា ៩២.៩% កំពុងធ្វើការ និងស្នាក់នៅប្រទេសថៃ ហើយប្រមាណជា ៧,១% ផ្សេងទៀត នៅក្នុងប្រទេសម៉ាឡេស៊ី អារ៉ាប៊ីសាអូឌីត ជប៉ុន សិង្ហបុរី-តំបន់រដ្ឋបាលពិសេសហុងកុង និងសាធារណ រដ្ឋកូរ៉េ។

## ២.២. កំណើនសេដ្ឋកិច្ចកម្ពុជា

នៅក្នុងរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០១៩របស់ធនាគារពិភពលោកដែលបង្ហាញថាកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច ៧,៥ភាគរយនៅក្នុងឆ្នាំ២០១៨ ដែលជាអត្រាកំណើនល្អ ជាងការរំពឹងទុកទៅទៀត បើធៀបនឹងអត្រាកំណើន៧%នៅក្នុងឆ្នាំ២០១៧។ ដោយមានការជំរុញមួយផ្នែកធំពីរ ការកើនយ៉ាងរហ័សនៃការនាំចេញ និងការបន្តលូតលាស់នៃវិស័យសំណង់ បូករួមទាំងតម្រូវការក្នុងស្រុកមានកម្រិតខ្ពស់ជាងមុន។ ការនាំចេញកើនឡើងយ៉ាងឆាប់រហ័សដោយសារតែតម្រូវការខាងក្រៅ ជាពិសេសការនាំចេញទៅទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប មានភាពរឹងមាំ។ ដោយឡែកការនាំចេញសម្លៀកបំពាក់ និងស្បែកជើងដែលមានចំនួនពីរភាគបីនៃការនាំចេញទំនិញសរុបកើនឡើងពី ៨.៣%នៅក្នុងឆ្នាំ២០១៧ ដល់ ១៧.៦%នៅក្នុងឆ្នាំ២០១៨។ ទំនុកចិត្តអ្នកប្រើប្រាស់ទំនិញមានការកើនឡើង ដែលធ្វើឲ្យមានកំណើននៃការនាំចូល ជាពិសេសការនាំចូលរថយន្តដែលមានការកើនឡើងនៅក្នុងអត្រា ៥០% និង ៤៨% សម្រាប់ការនាំចូល ដែកសំណង់ វិស័យសំណង់ អចលនទ្រព្យ និងទេសចរណ៍ សរុបមកមានចំណែក៦០ភាគរយ នៃចំនួនគម្រោងវិនិយោគទាំងអស់ដែលត្រូវបានអនុម័តរួចក្នុងឆ្នាំ ២០១៨។ ការផលិតសម្ភារផ្គត់ផ្គង់ការសាងសង់ ដែក គ្រឿងសង្ហារឹម និងផលិតផលប្លាស្ទិចក៏មានការកើនឡើងយ៉ាងលឿនដែរ ដើម្បីគាំទ្រដល់ការលូតលាស់របស់វិស័យសំណង់។

ចន្លោះពីឆ្នាំ ២០១៨ ទៅ ២០២១ យើងនឹងសង្កេតឃើញនូវនិន្នាការតម្រូវការកម្លាំងពលកម្មតា អនុស័យដូចខាងក្រោមះ

- អនុវិស័យសេដ្ឋកិច្ចដែលនឹងបង្កើតការងារច្រើនជាងគេគឺ សំណង់(៦៣ ៦៥៦នាក់ ក្នុងមួយឆ្នាំ) និង ទី២គឺកម្មន្តសាលផ្សេងៗ ( ៦០ ៨៦៩ ក្នុងមួយឆ្នាំ)។ ការកើនឡើងនៃតម្រូវការកម្លាំងពលកម្មនៅក្នុង អនុវិស័យកម្មន្តសាលផ្សេងៗ ជាសញ្ញាណនៃពិពិធកម្មនៅក្នុងសេដ្ឋកិច្ច។
- អនុវិស័យដែលនឹងមានអត្រាកំណើនការងារលឿន (អត្រាកំណើន២ខ្ទង់ ក្នុងមួយឆ្នាំ)មានដូចជា កម្មន្តសាលផ្សេងៗ (២១,៦%) ផលិតផលជ័រកៅស៊ូ និងប្លាស្ទិក (១,២០%) និងហិរញ្ញវត្ថុនិងធានារ៉ាប់រង (១២,២%)។
- អនុវិស័យ ៣ ដែលនឹងមានចំនួនការងារធ្លាក់ចុះច្រើនជាងគេ ដំណាំ (៧៨ ០៩១នាក់ ក្នុងមួយឆ្នាំ), រុក្ខា ប្រមាញ់ ( ១៦ ៤៨១ នាក់), និងសេវាកម្មផ្សេងៗ (១០ ៣២៩ នាក់)។

## ២.២.១. កំណើនផលិតផលក្នុងស្រុកសរុប(GDP)

ផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសកម្ពុជាមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ និន្នាការនៃការកើនឡើងនេះបានបង្ហាញពីការរីកចម្រើន និងភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា។ ជាក់ស្តែងនៅក្នុង ឆ្នាំ២០០៩ ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា មានចំនួន ១០ ៦០៩ ៦១៥ លានដុល្លារអាមេរិក ដែលកើនដល់ ១៩ ៥៨១ ៦៧២ លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៨ និង ២៤ ៥៧២ ២៣៣លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៩។ មូលហេតុនៃការកើនឡើងនេះ ត្រូវបានគេសង្កេតឃើញបានមកពីវិស័យ៤ធំៗ ដែលមានដូចជា វិស័យឧស្សាហកម្មបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការរួមចំណែកសាងកំណើនសេដ្ឋកិច្ចកម្ពុជាដែលមានការកើន ឡើងគួរឲ្យកត់សម្គាល់ ពោលគឺ ២២.៩%នៃផលិតផលក្នុងស្រុកសរុប(GDP) នៅក្នុងឆ្នាំ២០១២ កើនដល់ ២៦.២%នៃផលិតផលក្នុងស្រុកសរុប(GDP) នៅក្នុងឆ្នាំ២០១៥។ ខណៈដែលវិស័យកសិកម្មមានការធ្លាក់ចុះពី៣៣.៥% នៃផលិតផលក្នុងស្រុកសរុប(GDP) នៅក្នុងឆ្នាំ២០១២មកត្រឹម២៩%នៅក្នុងឆ្នាំ២០១៥។ ចំពោះ វិស័យសំណង់វិញ ក៏មានការកើនឡើងគួរឲ្យកត់សម្គាល់ដែរ ពោលគឺពី៦.៥%នៅក្នុងឆ្នាំ២០១២ ទៅ ៨.៨%នៅក្នុងឆ្នាំ២០១៥ និងនៅតែរក្សាកំណើនកើនឡើងជាពៀងរាល់ឆ្នាំ។ ចំណែកឯវិស័យសេវាកម្មវិញ បានរួមចំណែកក្នុងការកសាងកំណើនGDPចំនួន ៣៩.៤%ឯណោះនៅក្នុងឆ្នាំ២០១៥។

ក្រាហ្វ២.២. បង្ហាញពីនិន្នាការនៃកំណើនផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាចាប់ពីឆ្នាំ ២០១៣ ដល់ ២០១៩ (គិតជាលានដុល្លា)




ប្រភព៖ធនាគារពិភពលោក(https://data.worldbank.org/indicator/NY.GDP.MKTP.CD?locations=KH)

## ២.២.២. ផលិតផលក្នុងស្រុកក្នុងប្រជាជនម្នាក់ៗ

ស្របពេលដែលកំណើនសេដ្ឋកិច្ចកម្ពុជាមានការរីកលូតលាស់យ៉ាងឆាប់រហ័សនា២ទសវត្សន៍ចុងក្រោយនេះ គេក៏សង្កេតឃើញពីនិន្នាការនៃការកើនឡើងផងដែរ នៃចំណូលរបស់ប្រជាពលរដ្ឋខ្មែរម្នាក់ៗអាចរកបាននៅក្នុងមួយឆ្នាំៗ។ តាមការអង្កេតរបស់ធនាគារពិភពលោក(World Bank) បានបង្ហាញថា នៅក្នុងឆ្នាំ ២០១៣ ផលិតផលក្នុងស្រុកសរុបរបស់ប្រជាជនម្នាក់ៗមានចំនួនតែ ៩២២.៨៩០ ដុល្លារអាមេរិកប៉ុណ្ណោះ។ ចំនួននេះមានការកើនឡើងដល់ ១,៦៤៣.១២១ ដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៩ ដែលជាតួលេខមួយស្របទៅនឹង គោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជារបស់រដ្ឋាភិបាលកម្ពុជានឹងធ្វើការកែប្រែប្រទេសកម្ពុជាដែលមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលកម្រិតខ្ពស់នៅក្នុងឆ្នាំ២០៥០។

ក្រាហ្វ២.៣. បង្ហាញពីនិន្នាការនៃកំណើនផលិតផលក្នុងស្រុកម្នាក់ៗរបស់កម្ពុជាចាប់ពីឆ្នាំ ២០១៣ ដល់ ២០១៩ (គិតជាដុល្លា)




ប្រភព៖ធនាគារពិភពលោក(https://data.worldbank.org/indicator/NY.GDP.MKTP.CD?locations=KH)

# ជំពូកទី៣

# ការសិក្សាលើលទ្ធផល
# ស្រាវជ្រាវ

# ជំពូកទី៣ ការសិក្សាលើលទ្ធផលនៃការស្រាវជ្រាវ

## ៣.១. គុណសម្បត្តិរបស់វិស័យការងារ

ដោយការខិតខំប្រឹងប្រែងរបស់ រដ្ឋាភិបាលនិងថ្នាក់ដឹកនាំរបស់វស័យការងារដែលមានដូចជា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួងពាក់ព័ន្ធដទៃទៀតក្នុងវិស័យការងារបានសម្រេចនូវសមិទ្ធផលជាច្រើនដូចជា

- បានធ្វើវិសោធនកម្មបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងរៀបចំបន្ថែមនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារឱ្យស្របតាមការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច សង្គម និងបទដ្ឋានអន្តរជាតិ ជាពិសេសបានរៀបចំ កសាងច្បាប់ស្តីពីសហជីព នៅឆ្នាំ២០១៦ និងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា នៅក្នុងឆ្នាំ ២០១៨
- បានកែសម្រួលយន្តការអធិការកិច្ចការងារ ពីការធ្វើអធិការកិច្ចការងារជាច្រើនក្រុមដាច់ដោយឡែកពីគ្នា តាមជំនាញនីមួយៗមកជាក្រុមអធិការកិច្ចការងាររួមគ្នា
- បានបង្កើតប្រព័ន្ធគ្រប់គ្រងសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត
- បានកែលម្អរបាយការណ៍អធិការកិច្ចការងារឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ តម្លាភាព និងទទួល បានការ ជឿទុកចិត្តពីគ្រប់ភាគីពាក់ព័ន្ធស្របតាមច្បាប់ជាធរមាន និងស្តង់ដាអន្តរជាតិ ព្រមទាំងការពង្រឹងសមត្ថភាពមន្ត្រី និងគុណភាពអធិការកិច្ចការងារតាមរយៈបន្តគាំទ្រគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងកិច្ចសហការជាមួយ ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់
- បានរៀបចំបង្កើតវិទ្យាស្ថានជាតិការងារដែលនឹងដាក់ឱ្យដំណើរការនៅឆ្នាំ ២០១៩នេះ ក្នុងគោលបំណង អភិវឌ្ឍសមត្ថភាព និងផ្តល់វិក្រឹត្យការដល់មន្ត្រីរាជការក្នុងវិស័យការងារ
- បានបន្តអនុវត្តយន្តការក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈដើម្បីសម្របសម្រួលទទួលយកយោបល់ស្តីអំពីលក្ខខណ្ឌការងារ និងការដោះស្រាយបញ្ហាទាក់ទងនឹងទំនាក់ទំនងវិជ្ជាជីវៈ
- បានពង្រឹងគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា គ្រប់ជាន់ថ្នាក់ និងអគ្គ លេខាធិការដ្ឋាន ដើម្បីប្រចាំការត្រៀមខ្លួនអន្តរាគមន៍ទប់ស្កាត់ ដោះស្រាយ និង ផ្សះផ្សាវិវាទ ព្រមទាំងបើកវគ្គបណ្ដុះប ណ្តាលពង្រឹងសមត្ថភាពមន្ត្រី គ.ក.ប និងអាជ្ញាធរពាក់ព័ន្ធ សរុបចំនួន ៣. ៦៩៧នាក់ ស្មើនឹង ១៨ វគ្គ និងអន្តរាគមន៍ ដោះស្រាយកូដកម្មចំនួន ១,០២២ លើ ១០៤២ករណី (ស្មើនឹង ៩៨,១%) ដែលជាលទ្ធផល់ ករណីសះជាមានចំនួន ១ ០០៨ ករណី (ស្មើនឹង ៩៦,៧% នៃចំនួនកូដកម្មសរុប ចំនួនករណីកូដកម្មដែលកើតឡើងនៅតាមសហគ្រាស គ្រឹះស្ថាន បានថយចុះជាបន្តបន្ទាប់ប្រមាណជា ៨៦,២ % ពោលគឺថយចុះពី ៣៤២ ទៅ ៤៧ ក្នុងចន្លោះ

ឆ្នាំ២០១៤ និង២០១៨ និងអត្រាកូដកម្មដែលឈានទៅដល់ហិង្សាស្ថិតនៅក្នុងកម្រិតទាបនិងគ្រប់គ្រងបានប្រមាណជា ៤,១%

▪ បានដោះស្រាយវិវាទការងារចំនួន ៤ ២៧២ករណី ក្នុងនោះវិវាទបុគ្គលចំនួន ១៤៥៣ ករណី និងវិវាទ ការងាររួមចំនួន ២ ៨១៩ ករណី។ ជារួម យន្តការ និងសមត្ថភាពមន្ត្រីក្នុងការដោះស្រាយវិវាទការងារត្រូវបានកែ លម្អ និងមានប្រសិទ្ធភាពជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះនៃចំនួនវិវាទការងាររួមពី ៨៧៥ មកត្រឹម ១៦៣ ករណី នៅចន្លោះឆ្នាំ ២០១៤-២០១៨។

▪ បានពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា តាមរយៈយន្តការត្រីភាគី និងបង្កើតក្រុមការងារបច្ចេកទេសត្រីភាគី។ ដើម្បីពិភាក្សាការងារបច្ចេកទេសលម្អិតលើលក្ខណវិនិច្ឆ័យបែបសង្គម និងសេដ្ឋកិច្ច ព្រមទាំងរក្សានូវអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតក្នុងវិស័យ វាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងបន្ថែមលើប្រាក់ឈ្នួលអប្បបរមាដែល រួមមាន ប្រាក់រង្វាន់ធ្វើការទៀង ទាត់ចំនួន ១០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែប្រាក់សោហ៊ុយធ្វើដំណើរ ឬស្នាក់នៅចំនួន ៧ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ និងប្រាក់រង្វាន់អតីតភាពការងារដែលទទួលបានចន្លោះពី ១ ទៅ ១១ដុល្លារសហរដ្ឋអាមេរិកក្នុង មួយខែ

▪ បានដំឡើងប្រាក់ឈ្នួលអប្បបរមាពី ១០០ ដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ២០១៤ ដល់ ១៧០ដុល្លារសហ រដ្ឋអាមេរិ កនៅឆ្នាំ២០១៨ សម្រាប់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ហើយ សម្រាប់ឆ្នាំ ២០១៩ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតក្នុងវិស័យនេះ កើនឡើងដល់ ១៨២ ដុល្លា សហរដ្ឋអាមេរិក ប្រសិនបើបូកនឹងប្រាក់អត្ថប្រយោជន៍បន្ថែម កម្មករនិយោជិតម្នាក់អាចទទួលបាន ប្រាក់ឈ្នួលពី ១៩៩ ទៅ ២១០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ

▪ បានរៀបចំគោលនយោបាយស្ដីពីទេសន្តរប្រវេសន៍ដែលផ្ដោតសំខាន់លើអភិបាលកិច្ចនៃទេសន្តរប្រវេសន៍ការការពារ និងការលើកកម្ពស់សិទ្ធិរបស់ ពលករទេសន្តរប្រវេសន៍ និងការរៀបចំទេសន្តរប្រវេសន៍ការងារដើម្បីអភិវឌ្ឍន៍

▪ បានផ្ដល់សេវារកការងារនៅក្រៅប្រទេស ជូនប្រជាពលរដ្ឋចំនួន ១,២ លាននាក់ ដែលក្នុងនោះនៅ ប្រទេសថៃចំនួន ១ ១៤៦ ៦៨៥ នាក់, ម៉ាឡេស៊ីចំនួន ៣០ ១១៣ នាក់, អារ៉ាប់ប៊ីសាអូឌីតចំនួន ១៦ នាក់, ជប៉ុនចំនួន ៧៣១៣ នាក់, សិង្ហបុរីចំនួន ៨៣១ នាក់, តំបន់រដ្ឋបាលពិសេសហុងកុងចំនួន ៥៤ នាក់, និងសាធារណរដ្ឋកូរ៉េចំនួន ៤៩ ០៩៩ នាក់

▪ និងស្វែងរកការងារ បង្កើតការងារ និង អភិវឌ្ឍន៍សមត្ថភាព កម្មករលើវិស័យនានា ដូចជា វិស័យកសិកម្ម សំណង់ វិស័យវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង និងវិស័យផ្សេងៗទៀត។

## ៣.២.បញ្ហាប្រឈមក្នុងទីផ្សារការងារ

ដោយផ្អែកលើទិន្នន័យដែលបានបង្ហាញខាងលើ ទីផ្សារការងារកម្ពុជាកំពុងតែប្រឈមនឹងបញ្ហាសំខាន់ៗមួយចំនួនដូចខាងក្រោម៖

១. ប្រមាណ ៥០,៨% នៃអ្នកដែលមានការងារសរុបកំពុងតែបម្រើការងារក្នុងទម្រង់ការងារជាអ្នកប្រើទុន ដោយខ្លួនឯង ឬជួយការងារគ្រួសារដោយមិនទទួលប្រាក់កម្រៃ ដែលប្រភេទការងារទាំងអស់នេះត្រូវបានចាត់ ទុកជាការងារក្រៅផ្លូវការ ហើយអាចប្រឈមទៅនឹងលក្ខខណ្ឌការងារទាប។ ក្នុងន័យនេះ ការជំរុញការបង្កើត ការងារសមរម្យ និងមានផលិតភាពខ្ពស់ ជាពិសេសនៅវិស័យក្រៅពីកសិកម្ម គឺជាការចាំបាច់សម្រាប់កម្ពុជា។

២. តាមរយៈការពិនិត្យ និងការវិភាគទៅលើស្ថានភាពប្រជាសាស្ត្រ ការទទួលបានការអប់រំ និងជំនាញ និងតម្រូវការជំនាញនៅផ្នែកខាងលើ យើងអាចសង្កេតឃើញថា ភាពមិនបន្សុំគ្នានៃជំនាញកំពុងតែកើតមានឡើង នៅក្នុងទីផ្សារការងារនៃប្រទេសកម្ពុជា ជាពិសេសនៅក្នុងជំនាញកម្រិតមធ្យម និងខ្ពស់។ បញ្ហានេះបានបណ្តាល ឱ្យនិយោជកបាននឹងកំពុងប្រឈមការលំបាក ក្នុងការជ្រើសរើសកម្លាំងពលកម្មដើម្បីបំពេញតាមតម្រូវការរបស់ខ្លួន ដែលបណ្តាលមកពីបញ្ហាកង្វះជំនាញនៅលើទីផ្សារការងារ (skill shortages) និងគម្លាតជំនាញ (skill gaps) ដោយសារបេក្ខជនដែលមកដាក់ពាក្យខ្វះជំនាញ, និងបទពិសោធន៍ការងារតាមតម្រូវការរបស់និយោជក់។ ហេតុដូច្នេះ ការពង្រឹង និងពង្រីកការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេសកម្លាំងពលកម្ម ដែលកំពុងធ្វើការ គឺមានសារៈ សំខាន់ក្នុងការធ្វើឱ្យ ប្រសើរឡើងនូវជំនាញនៃកម្លាំងពលកម្មកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការកម្លាំងពលកម្មជំនាញកម្រិតមធ្យម និងខ្ពស់ទាំងនៅក្នុងប្រទេស និងក្នុងតំបន់ដែលកំពុងត មានការកើនឡើង។

៣. ទីផ្សារការងារមិនទាន់ដំណើរការល្អ ដោយសាររបាយកម្លាំងពលកម្មបិនស្មើគ្នា (រវាងទីប្រជុំជន និង ជនបទ), សេវាអន្តរកម្មការងារ និងការបែងចែកព័ត៌មានមិនទាន់មានការអភិវឌ្ឍពេញលេញ និងប្រព័ន្ធព្យាករណ៍ និងប៉ាន់ស្មានទៅអនាគតអំពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងជំនាញ និងការងារមិនទាន់ត្រូវបានអភិវឌ្ឍ។ នេះបានបង្ហាញថា ការអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម រួមមានការពង្រីកការផ្តល់សេវាការងារសាធារណៈ ការពង្រឹងយន្តការវេទិកាការងារ និងការតម្រង់ទិសមុនចូលទីផ្សារការងារ គឺដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យ ប្រសើរឡើងនូវដំណើរការទីផ្សារការងារ តាមរយៈ ការធ្វើឱ្យមានតម្លាភាពរវាងការផ្គត់ផ្គង់ និងតំម្រូវការនៅលើ ទីផ្សារការងារ និងផ្តល់ភាពងាយស្រួលឆាប់រហ័ស ក្នុងការផ្គូផ្គងរវាងអ្នកស្វែងរកការងារ និងព័ត៌មានជ្រើសរើស កម្លាំងពលកម្ម។ បន្ថែមពីលើនេះ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ ដែលដើរតួនាទីក្នុងការប្រមូល ផ្សព្វផ្សាយ វិភាគ វាយតម្លៃ និង ផ្តល់ព័ត៌មានទីផ្សារឱ្យបានទៀងទាត់ទាន់ពេលវេលា និងទូលំទូលាយ រួមទាំងការងារ ពាក់ព័ន្ធនឹងការកែលម្អស្ថានភាពទីផ្សារការងារ នៅ ក្នុងវិស័យដែលត្រូវការបន្ថែមកម្លាំងពលកម្ម នឹងដើរតួកាន់ តែសំខាន់ក្នុងការធានាថា ប្រជាជនដែល

មាន ជំនាញ និងបទពិសោធន៍ការងារស្រាប់នឹងមានលទ្ធភាពទទួលបានឱកាសការងារប្រសើរជាងមុន នៅតាមបណ្តារិ ស័យសេដ្ឋកិច្ចដែលមានការរីកចម្រើន។

៤. ការប្រែក្លាយកម្លាំងពលកម្មភាគច្រើននៅតែស្ថិតក្នុងវិស័យកសិកម្ម និងទទួលបានការអប់រំក្រោមថ្នាក់ បឋមសិក្សា ទៅបម្រើការឱ្យវិស័យឧស្សាហកម្ម និងសេវាកម្ម ទាមទារការផ្លាស់ប្តូរសំខាន់មួយក្នុងទីផ្សារការងារ រួមមានរបៀបរបប នៃការជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាលជំនាញ វិន័យ ឥរិយាបថការងារ បណ្តុះទម្លាប់ ជាពិសេស ទំនាក់ ទំនងវិជ្ជាជីវៈដែលមានភាពសុខដុម និងរឹងមាំដែលគាំទ្រដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធ និងបែង ចែកអត្ថប្រយោជន៍ ដែលកើតពីកំណើនសេដ្ឋកិច្ចរវាងនិយោជិត និងនិយោជក ប្រកបដោយសមធម៌។ ប៉ុន្តែ ទំនាក់ ទំនងវិជ្ជាជីវៈប្រកបដោយភាពសុខដុមរមនា និងធានាភាពអាចព្យាករបានរវាង កម្មករនិយោជិត និងនិយោជក នៅមិនទាន់បានអភិវឌ្ឍពេញលេញ និងមានភាពចាស់ទុំនៅឡើយទេ។

៥. មូលដ្ឋាននៃកំណើន និងការងារតូចចង្អៀត បានឆ្លុះបញ្ចាំងពីកម្លាំងពលកម្មមានលក្ខណៈ ប្រមូលផ្តុំ និងពឹងផ្អែកទៅលើតែវិស័យមួយចំនួនតូច។ ទន្ទឹមគ្នានេះ កំណើនប្រាក់ឈ្នួលមិនសមស្រប នឹងកំណើនផលិត ភាពបាននឹងកំពុងដាក់សម្ពាធលើល្បឿន នៃការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចចេញពីការពឹងផ្អែកលើឧស្សាហកម្ម អតិពលកម្មទៅឧស្សាហកម្មដែលផ្អែកលើជំនាញ និងមានតម្លៃបន្ថែមកាន់តែខ្ពស់។ ប្រការនេះតម្រូវឱ្យមានការ វិនិយោគនៅគ្រប់កម្រិតក្នុងបង្កើនផលិតភាព ដែលចាប់ពីកម្រិតថ្នាក់ជាតិ កម្រិតសហគ្រាស និងកម្រិតបុគ្គល។ ប៉ុន្តែការបង្កើនផលិតភាពការងារ ដែលប្រចាំបំផុតគឺនៅកម្រិតបុគ្គលិក ដែលនេះទាមទារទាំងការវិនិយោគទៅ លើវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលក្នុងពេលធ្វើការងារ។ ប៉ុន្តែកិច្ច ការដំបូងចាំបាច់បន្ទាន់ដែលចាំបាច់ត្រូវធ្វើ គឺការបង្កើតឡើងនូវផ្នត់គំនិតជាមូលដ្ឋានអំពីផលិតភាព ភាពចាំបាច់ និងសារប្រយោជន៍របស់វាក្នុងការលើកកម្ពស់ភាពប្រកួតប្រជែង ឬការទ្រទ្រង់កំណើនរយៈពេលវែង ការបង្កើតការងារ កាន់តែល្អ និងការបន្តលទ្ធភាពដំឡើងប្រាក់ឈ្នួលកាន់តែខ្ពស់។

៦. ការលេចឡើងនូវបដិវត្តន៍ឧស្សាហកម្មទី៤.០ បាននាំឱ្យតម្រូវការជំនាញកាន់តែខ្ពស់ ដែលនេះអាចនឹង បង្កឱ្យមានបញ្ហាកង្វះជំនាញ ព្រមទាំងការជំនួសកម្លាំងមនុស្សដោយម៉ាស៊ីនស្វ័យប្រវត្តិកម្ម និងបញ្ញាសិប្បនិម្មិត ដែលនេះអាចនាំឱ្យបាត់បង់ការងារ ជាពិសេសសម្រាប់កម្លាំងពលកម្មជំនាញទាប និងគ្មានជំនាញ។ ហេតុដូចនេះ ដើម្បីត្រៀមលក្ខណៈទប់ទល់នឹងបញ្ហាប្រឈម និងទាញប្រយោជន៍ជាអតិបរមាពីបដិវត្តន៍ឧស្សាហកម្មទី៤.០នេះការលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងជំរុញការ ស្រាវជ្រាវ និងនវានុវត្តន៍ បច្ចេកវិទ្យាអនុវត្តន៍ គឺជាការចាំបាច់ក្នុងការទាញយកផលប្រយោជន៍ ភាពរីកចម្រើនន បច្ចេកវិទ្យា និងនវានុវត្តលើឧស្សាហកម្មដែលមានស្រាប់។

៧. ដោយសារអតុល្យភាពប្រជាសាស្ត្រ ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងតំបន់មានកម្រិតផ្សេងគ្នា កំណើនទេសន្តរប្រវេសន៍នឹងបន្តកើនឡើង ដែលអាចបណ្តាលឱ្យកើតមានឡើងការខ្វះខាតកម្លាំងពលកម្មក្នុងប្រទេសនិង ការកើនឡើងប្រាក់ឈ្នួលក្នុងស្រុកលឿន។ ទន្ទឹមនឹងនិន្នាការនេះ បញ្ហាប្រឈម គឺការគ្រប់គ្រង ការពារសិទ្ធិ ផលប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍ខ្មែរនៅក្រៅប្រទេស។

៨. តម្រូវការកាន់តែកើនឡើង ក្នុងការពង្រីករបបសន្តិសុខសង្គមទៅវិស័យក្រៅផ្លូវការព្រមទាំងពង្រីក ប្រភេទរបបសន្តិសុខ និងសង្គមដើម្បីធានាស្ថិរភាពការងារ និងចំណូលរបស់ប្រជាពលរដ្ឋ។

## ៣.៣. ឥទ្ធិពលវិស័យការងារលើកំណើនសេដ្ឋកិច្ច

### ៣.៣.១.ទំនាក់ទំនងរវាងកំណើនការងារ និងកំណើនសេដ្ឋកិច្ច




| | កសិកម្ម | ឧស្សាហកម្ម | សេវាកម្ម |
|---|---|---|---|
| GDP | 1.7 | 10.2 | 7 |
| កំណើនការងារ | -2.6 | 6.7 | 3.3 |

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

យោងតាមតាមទិន្នន័យខាងលើបានបង្ហាញថាក្រោមការចូលរួមជ្រំជ្រែងយ៉ាងសកម្មពីសណាក់រដ្ឋាភិបាល ដែលមានដូចជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាក់ព័ន្ធផ្សេងៗបាន ស្វែងរកវិនិយោគទុន ដើម្បីបង្កើត និងអភិវឌ្ឍន៍វិស័យសំខាន់ៗដែលមានដូចជា វិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ដែលធ្វើអោយវិស័យទាំងនេះមានកំណើនការងារជាច្រើនដូចជា វិស័យកសិកម្មមានកំណើនការងារជាសរុបនៅក្នុងឆ្នាំ២០១៨ ដល់ឆ្នាំ ២០២១មានចំនួន -2,6% និងរួមចំណែក១,៧%នៃកំណើនផលិតផលក្នុងស្រុកសរុប ចំណែកឧស្សាហកម្មវិញមានការកើនឡើងទំហំការងារចំនួន៦,៧% និងរួមចំណែក១០,២% នៃកំណើនផលិតផលក្នុងស្រុកសរុប និងសេវាកម្មមានកំណើនការងារជាសរុបនៅក្នុងឆ្នាំ២០១៨ ដល់ ឆ្នាំ ២០២១មានចំនួន7% និងរួមចំណែក៣,៣% នៃកំណើនផលិតផលក្នុងស្រុកសរុប។ ដោយគិតតែលើវិស័យសំខាន់ៗទាំងបីនេះទំហំការងាររបស់ប្រទេសកម្ពុជានៅចន្លោះឆ្នាំ២០១៨ ដល់ឆ្នាំ២០២១មានការកើនឡើងសរុបចំនួន ២១៦ ៤៦៥ កន្លែង និមានកំណើនផលិតផលក្នុងស្រុកសរុប(GDP) ៧,២%ជាមធ្យមនៅក្នុង១ឆ្នាំ។

## ៣.៣.២.ឥទ្ធិពលវិស័យការខារនៅលើប្រាក់ឈ្នួលកម្មករ ( wage ) និង ផលិតផលជាតិសរុប ( GDP )

### ផលិតផលជាតិសរុប ( GDP )

ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះសេដ្ឋកិច្ចកម្ពុជាគឺជាផ្នែកមួយនៃកំណើនសេដ្ឋកិច្ចលឿន បំផុតរបស់ពិភពលោកចាប់តាំងពីឆ្នាំ ២០០១ កំណើនផលិតផលក្នុងស្រុកសរុបពិតប្រាកដមានជាមធ្យម៧% ក្នុងមួយឆ្នាំ ហើយយ៉ាងហោចណាស់ ៦,៧% រាល់ឆ្នាំលើកលែងតែឆ្នាំ ២០១៩ ក្នុងសកលលោក សេដ្ឋកិច្ចធ្លាក់ចុះ។ សេដ្ឋកិច្ចត្រូវបានព្យាករថានឹងរក្សាបាននូវកំណើនដ៏រឹងមាំអត្រា ៧% រហូតដល់ឆ្នាំ ២០១៧ មុនពេលមានការថយចុះបន្តិចមកត្រឹម ៦,៨% ក្នុងឆ្នាំ ២០១៨ និង ៦,៧% នៅឆ្នាំ ២០១៩។ កំណើននេះបានធ្វើ អោយសេដ្ឋកិច្ចក្នុងប្រទេសមានភាពល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំគួរអោយកត់សម្គាល់ផងដែរ ។

### កម្រិតប្រាក់បៀវត្សន៍( Wage )

នៅក្នុងរយៈពេលដូចគ្នា ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង បានកើនឡើងជាលំដាប់ ពោលកើនឡើងពី ១០០ ដុល្លារសហរដ្ឋអាមេរិក នៅឆ្នាំ២០១៤ ដល់ ១៧០ ដុល្លារសហរដ្ឋ អាមេរិក នៅឆ្នាំ២០១៨ ហើយសម្រាប់ឆ្នាំ២០១៩ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតក្នុងវិស័យនេះកើនឡើងដល់១៨២ដុល្លារសហរដ្ឋអាមេរិក។បើធ្វើការប្រៀបធៀបជាមួយបណ្តាលប្រទេសដែលមានស្ថានភាព សេដ្ឋកិច្ចសង្គម ប្រហាក់ប្រហែលគ្នា និងជាដៃគូប្រកួតប្រជែង ចាប់ពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៩ ប្រាក់ឈ្នួលអប្បបរមា នៅកម្ពុជាបានកើនឡើងជាលំដាប់ប្រមាណជា ១៦,៣% ជាមធ្យមក្នុងមួយឆ្នាំ។

**តារាង៣.១.បង្ហាញពី** wage **និង** GDP

| **ឆ្នាំ** | **GDP(%)** | **Wage($)** |
|---|---|---|
| ២០១៣ | ៧.៤ | ៨០ (១៦%) |
| ២០១៤ | ៧.១ | ១០០ (25%) |
| ២០១៥ | ៧ | ១២៨ (28%) |
| ២០១៦ | ៧ | ១៤០ (9.៣%) |
| ២០១៧ | ៧ | ១៥៣ (៩.២) |
| ២០១៨ | ៦.៨ | ១៧០ (១១.១១%) |
| ២០១៩ | ៦.៧ | ១៨២ (៧%) |

ប្រភព៖ (Cambodia Economy in charts, 2021)

# ការវិភាគទិន្នន័យ




| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 |
|---|---|---|---|---|---|---|---|
| GDP | 7.4 | 7.1 | 7 | 7 | 7 | 6.8 | 6.7 |
| Wage | 80 | 100 | 128 | 140 | 153 | 170 | 182 |

យោងតាមតារាងទិន្នន័យខាងលើបានបង្ហាញយើងអោយឃើញថាប្រាក់បៀវត្តន៍របស់កម្មករ និង កម្មការនីនយោជិក ទៅតាមវិស័យនានានៅក្នុងប្រទេសកម្ពុជាមានប្រាក់ប្រាក់បៀវត្តន៍កើនឡើងពីមួយឆ្នាំ ទៅ មួយឆ្នាំ ដោយមានការជួយគាំទ្រពីសំណាក់ រាជរដ្ឋាភិបាល ក៏ដូចជាការជួយជ្រុំជ្រែងពីសំណាក់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផងដែរ។ យើងសង្កេតឃើញថានៅឆ្នាំ ២០១៣ ប្រាក់បៀវត្តន៍របស់កម្មករ និង កម្មការនីនយោជិក ទៅតាមវិស័យនានានៅក្នុងប្រទេសកម្ពុជាមានចំនួនត្រឹមតែ ៨០ ដុល្លាតែប៉ុណ្ណោះ ប៉ុន្តែដោយការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល បានជំរុញអោយប្រាក់បៀវត្តន៍របស់កម្មករ និង កម្មការនីនយោជិកបានកើនឡើងដល់ ១០០ ដុល្លានៅឆ្នាំ ២០១៤ និងកើនឡើងជាបន្តបន្ទាប់រហូតដល់ ១៨២ ដុល្លានៅឆ្នាំ២០១៩។ ជាលទ្ធផលវិស័យការងារ ក៏ដូចជា ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈបានដើរតួនាទិយាងសំខាន់ដល់ការធ្វើអោយមានកំណើនប្រាក់បៀវត្តន៍របស់ កម្មករ និងកម្មការនីនិយោជិក ដែលជាផ្នែកមួយដ៏សំខាន់ដែលធ្វើអោយកម្ពុជាមានកំណើនសេដ្ឋកិច្ចជាមធ្យម ៧%ឥតឈប់ឈរពីមួយឆ្នាំ ទៅមួយឆ្នាំ។

# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្នុងការអភិវឌ្ឍន៍ការងារក្នុងវិស័យការងារនៅឆ្នាំ២០១៣-២០១៩ កន្លងមកនេះគឺទទួលបានសមិទ្ធផលគួរជាទីមោទនៈណាស់ តាមការចង្អុលទិសដៅក្រោមការដឹកនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមទាំងថ្នាក់ដឹកនាំរបស់ក្រសួង ជាមួយនឹង យុទ្ធសាស្រ្តកំណែទម្រង់ដ៏ត្រឹមត្រូវដែលបានដាក់ចេញនៅ គ្រប់អង្គភាព ក្រោមឱវាទរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជជីវៈ បានជំនះនូវរាល់បញ្ហាប្រឈម និង ឧបសគ្គទាំងឡាយដោយអនុវត្តប្រកបដោយភាពជោគជ័យនូវ សមិទ្ធផលសំខាន់ៗជាច្រើនជូនរាជរដ្ឋាភិបាល ក៏ដូចជាប្រជាជនកម្ពុជា។

ការសម្រេចបាននូវសមិទ្ធផលខាងលើនេះ ការអភិវឌ្ឍន៍វិស័យការងារ ក៏បានរួមចំណែកលើការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្រ្ត អភិវឌ្ឍន៍ជាតិឆ្នាំ២០១៣-២០១៩ ព្រមទាំងផែនការជាតិនានាដែលអាចជះឥទ្ធិពល មកលើកំណើនសេដ្ឋកិច្ច-សង្គមកិច្ច កម្ពុជាស្របតាមការវិវត្តនៃសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ជាពិសេសនៅក្នុងបរិបទអាស៊ាន និងសកលភាវូបនីយកម្ម ដែលវិស័យការងារបានបន្តការអភិវឌ្ឍន៍ និងរីកចម្រើន ដោយសម្រេចបានអត្រាមានការងារធ្វើប្រមាណ៩៩,៣%នៅក្នុងបរិមាណការងារសរុបនៃប្រជាជន១០លាននាក់នៅក្នុងប្រទេសកម្ពុជា និងវាក៏ជាចំណែកមួយដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចកម្ពុជាផងដែរ។

## ២.ការផ្តល់អនុសាសន៍

យោងតាមរបាយការណ៍ទិន្នន័យរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្ហាញថា បើទោះបីជារដ្ឋាភិបាលបានសម្រេចបាន នូវសមិទ្ធិផលបានជាច្រើននាពេលកន្លងមក និងបានរួមចំណែកដ៏សំខាន់ដល់ការជំរុញសេដ្ឋកិច្ចកម្ពុចជាក៏ពិតមែន។ តែនៅពីក្រោយការជោគជ័យនេះ រដ្ឋាភិបាលក៏ជួបប្រទះ
នូវបញ្ហាដ៏ស្មុគស្មាញជាច្រើនផងដែល។ ជាអនុសាសន៍របស់ខ្ញុំ ខ្ញុំយល់ឃើញថា វិស័យ ការងារ ត្រូវយកចិតទុកដាក់លើចំណុចសំខាន់ៗមួយចំនួនដូចជា៖

១. រាជរដ្ឋាភិបាលគួរបង្កើតបន្ថែមនូវកម្មវធីនានា ដើម្បីអភិវឌ្ឍន៍សមត្ថភាព កម្មករ កម្មការ និយោជិក

២. រាជរដ្ឋាភិបាលគួរបង្កើតច្បាប់ផ្សេងៗអោយបានតឹងរឹងដើម្បីការគ្រប់គ្រង វិស័យការងារ ផ្សេងៗដើម្បី កុំអោយមានការកេងប្រវ័ញ្ចលើកំលាំងពលកម្មរបស់កម្មករ កម្មការ និយោជិក

៣. នាំយកអ្នកវិនិយោគទុនពីក្រៅប្រទេស មកវិនិយោគទុននៅកម្ពុជាអោយបានច្រើនជាងនេះ ដើម្បីបង្កើន ទំហំការងារ ក៏ដូចជាប្រាក់ចំណូលផងដែរ។

# ឯកសារយោង

# ឯកសារយោង


(2021, 08 13). Retrieved from http://www.mlvt.gov.kh/

*Cambodia Economy in charts*. (2021, 08 13). Retrieved from EMERGING MARKET CONSULTING: https://emc-consulting.asia/2017/11/25/cambodia-economy-2017/

*http://www.mlvt.gov.kh/*. (2021, 08 13). Retrieved from http://www.mlvt.gov.kh/: http://www.mlvt.gov.kh/

*http://www.mlvt.gov.kh/index.php/%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99-%E1%9E%93%E1%9E%B7%E1%9E%84%E1%9E%95%E1%9F%82%E1%9E%93%E1%9E%80%E1%9E%B6%E1%9E%9A/58-%E1%9E%82%E1%9F%84%E1%9E%9B%E2%80%8B%E1%9E%93%E1%9E%99%*. (2021, 08 13). Retrieved from http://www.mlvt.gov.kh/index.php/%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99-%E1%9E%93%E1%9E%B7%E1%9E%84%E1%9E%95%E1%9F%82%E1%9E%93%E1%9E%80%E1%9E%B6%E1%9E%9A/1-%E1%9E%98%E1%9E%BB%E1%9E%81%E1%9E%9A%E1%9E%94%E1%9E%9A-%

Pettinger, T. (2019, 10 27). Retrieved from https://www.economicshelp.org/macroeconomics/economic-growth/causes-economic-growth/?fbclid=IwAR3aC9UYmfXg2cqhB3sTab6XmzNZYYUTYsjkq17Lp_vzWjkSN-xMD25SHZ8

https://ashraffeps.yolasite.com/resources/EuroMed/Fall2018/The%20main%20determinants%20affecting%20economic%20growth.pdf

http://www.mekongbiz.org/wp-content/uploads/2017/07/Cambodia-private-sector-assessment-report.pdf

https://www.immigration.gov.kh/international-new

ស្ុៀវសៅតផ្ការយ៉ុទ្យធសាស្រ្តអភិវ ឌ្ឍជន្យទ្យឆ្ ា ាំ ២០១៩ ដ្ល់ ២០២៣

Open Development Cambodia (ODC)

https://data.worldbank.org/indicator/NY.GDP.MKTP.CD?locations=KH

# ឧបសម្ព័ន្ធ




**តារាង ២.១៤÷ ការព្យាករកំណើនការងារតាមកម្រិតនៃការអប់រំ ចន្លោះឆ្នាំ ២០១៨ និង២០២១**

| កម្រិតនៃការអប់រំ | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ (2018-2021) | | | 2021 | |
|---|---|---|---|---|---|
| | ចំនួន | អត្រាចូលរួម(%) | អត្រាកំណើន (%) | ចំនួន (ពាន់នាក់) | បរិមាណភាគ (%) |
| ឧត្តមសិក្សា | 93,878 | 43.4 | 12.0 | 977 | 9.6 |
| មធ្យមសិក្សាទុតិយភូមិ | 76,777 | 35.5 | 11.1 | 854 | 8.4 |
| មធ្យមសិក្សាបឋមភូមិ | 79,863 | 36.9 | 4.6 | 1,894 | 18.6 |
| បឋមសិក្សា | 41,576 | 19.2 | 1.6 | 2,655 | 26.0 |
| មិនបញ្ចប់ថ្នាក់បឋមសិក្សា | -19,951 | -9.2 | -0.7 | 2,776 | 27.2 |
| គ្មាន ឬរៀនបានតិចតួច | -58,906 | -27.2 | -5.7 | 922 | 9.0 |
| ការអប់រំបណ្តុះបណ្តាលបច្ចេកទេស (មុន និងបន្ទាប់ពីមធ្យមសិក្សាទុតិយភូមិ) | 3,228 | 1.5 | 2.7 | 127 | 1.2 |
| សរុប | 216,465 | 100.0 | 2.2 | 10,204 | 100.0 |

ប្រភព÷ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើការអង្កេតសង្គមសេដ្ឋកិច្ចពី ឆ្នាំ១៩៩៣-២០១៧

## រូបភាព ២.១ ÷ ការវិវឌ្ឍប្រាក់ឈ្នួលអប្បបរមារបស់ប្រទេសកម្ពុជាធៀបនឹងបណ្តាប្រទេសជាដៃគូប្រកួតប្រជែងពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨




## តារាង ២.១២÷ ការព្យាករកំណើនការងារតាមវិស័យ ចន្លោះឆ្នាំ២០១៨ និង២០២១

| សកម្មភាពសេដ្ឋកិច្ច | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ (2018-2021) | | | 2021 | |
|---|---|---|---|---|---|
| | ចំនួន | អត្រាចូលរួម(%) | អត្រាកំណើន (%) | ចំនួន (ពាន់នាក់) | បរិមាណភាគ (%) |
| កសិកម្ម | (88,633) | -40.9 | -2.6 | 3,214 | 31.5 |
| ដំណាំ | (78,091) | -36.1 | -3.3 | 2,194 | 21.5 |
| សកម្មភាពចិញ្ចឹមសត្វ | 5,587 | 2.6 | 0.8 | 755 | 7.4 |
| រុក្ខាប្រមាញ់ | (16,481) | -7.6 | -16.4 | 69 | 0.7 |
| ការនេសាទ | 352 | 0.2 | 0.2 | 195 | 1.9 |
| ឧស្សាហកម្ម | 183,498 | 84.8 | 6.7 | 3,097 | 30.3 |
| ការជីករ៉ែ | (3,110) | -1.4 | -13.8 | 17 | 0.2 |
| កម្មន្តសាលផ្នែកផលិតចំណីអាហារ និងភេសជ្ជៈ | 9,807 | 4.5 | 4.8 | 224 | 2.2 |
| កម្មន្តសាលផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង | 52,527 | 24.3 | 4.6 | 1,251 | 12.3 |
| កម្មន្តសាលផ្នែកកែច្នៃឈើ ក្រដាស និងបោះពុម្ព | (6,462) | -3.0 | -8.3 | 65 | 0.6 |
| កម្មន្តសាលផ្នែកផលិតផលជ័រកៅស៊ូ និងប្លាស្ទិក | 1,174 | 0.5 | 12.0 | 12 | 0.1 |
| កម្មន្តសាលផ្សេងៗ | 60,869 | 28.1 | 21.6 | 411 | 4.0 |
| សំណង់ | 63,656 | 29.4 | 7.0 | 1,044 | 10.2 |
| ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន និងទឹក | 5,038 | 2.3 | 8.1 | 72 | 0.7 |
| សេវាកម្ម | 121,600 | 56.2 | 3.3 | 3,894 | 38.2 |
| ពាណិជ្ជកម្មលក់ដុំ និងរាយ | 57,058 | 26.4 | 4.5 | 1,395 | 13.7 |
| ការស្នាក់នៅ និងភោជនីយដ្ឋាន | 20,276 | 9.4 | 4.3 | 514 | 5.0 |
| ការដឹកជញ្ជូន ព័ត៌មានវិទ្យា និងគមនាគមន៍ | 13,104 | 6.1 | 2.7 | 517 | 5.1 |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 12,648 | 5.8 | 12.2 | 130 | 1.3 |
| រដ្ឋបាលសាធារណៈ | 10,242 | 4.7 | 3.2 | 337 | 3.3 |
| អចលនទ្រព្យ និងសេវាកម្មគាំទ្រអាជីវកម្ម | 18,601 | 8.6 | 3.7 | 539 | 5.3 |
| សេវាកម្មផ្សេងៗ | (10,329) | -4.8 | -2.1 | 463 | 4.5 |
| ចំនួនការងារសរុប | 216,465 | 100.0 | 2.2 | 10,204 | 100.0 |

ប្រភព÷ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្អែកលើអង្កេតសង្គមសេដ្ឋកិច្ចពីឆ្នាំ១៩៩៣-២០១៧